**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការផ្តល់ឥណទានរបស់ធនាគារ
# វឌ្ឍនៈ អាស៊ី ចំកាត់

កម្មសិក្សាពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន ៖ **ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ សាខាស្ទឹងមានជ័យ**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ព្រិច ណៃហុង**
**សួរ វិច្ឆ័យ**

សាស្ត្រាចារ្យណែនាំ
លោក **សួង ទេវនី**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ព្រិច ណៃហុង និង សួរ វិឆ្ល័យ ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ជំនាន់ទី ១៦ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៣-២០១៧។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការធ្វើអោយមានសមិទ្ធិផល នេះលេចចេញជារូបរាងឡើង ។ ជាពិសេសចពោះ**លោកឪពុក និងអ្នកម្ដាយ** ដែលជាអ្នកមានគុណយ៉ាងធំធេងរបស់យើងខ្ញុំទាំងពីរដោយលោក ទាំងពីរបានលះបង់ទាំងកម្លាំងកាយ និងចិត្ត ក្នុងការចិញ្ចឹមបីបាច់ អប់រំ ទូន្មាន ប្រៀនប្រដៅប្រកប ដោយព្រហ្មវិហារធម៌ល្អប្រពៃ ប្រព្រឹត្តតែអំពើល្អ និងធ្វើជាប្រយោជន៍ចំពោះខ្លួនឯង គ្រួសារ និងសង្គម ជាតិទាំងមូល។ ព្រមជាមួយគ្នានេះ លោកទាំងពីរបានជម្រុញ លើកទឹកចិត្តឲ្យយើងខ្ញុំខិតខំសិក្សា ដោយផ្តល់ ឰការជួយឧបត្ថម្ភ និងផ្គត់ផ្គង់យើងខ្ញុំទាំងពីរតាំងពីតូចរហូតមកដល់ថ្នាក់បរិញ្ញាបត្រ។

សូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ ចំពោះលោក**ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការ រងព្រឹទ្ធបុរស ប្រធានការិយាល័យ និងបុគ្គលិក ព្រមទាំងសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់** នៃសាកល វិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់នូវចំនេះដឹងជាច្រើនដើម្បីជា ប្រយោជន៍ និង ជាស្ពានឆ្ពោះទៅរកភាពជោគជ័យនាពេលបច្ចុប្បន្ន និងពេលអនាគត។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងវិសេសវិសាលចំពោះ **លោកសាស្ត្រាចារ្យ សូវ វេងនី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់គាត់ក្នុងការបង្ហាត់បង្រៀន ណែនាំ ផ្តល់មតិយោបល់ និងគំនិតល្អៗ ព្រមទាំងជួយដឹកនាំកែសម្រួលក្នុងកិច្ចការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សារបស់ក្រុមយើងខ្ញុំតាំងពីដើមរហូតរៀងមកហើយទទួលបានជោគជ័យជាស្ថាពរ។

លោកនាយក ដៃរជាជំណាងពេញសិទ្ធរបស់ ម៉្យាងវិញទៀត យើងខ្ញុំសូមអរគុណចំពោះ **ធនាគារវឌ្ឍនៈអាស៊ីចំកាត់ សាខាស្ទឹងមានជ័យ (Advanced Bank of Asia Limit, )** ដែលបានផ្តល់ឱកាសដល់យើងខ្ញុំបានធ្វើការស្រាវជ្រាវ និងផ្តល់ព័ត៌មានព្រមជាមួយឯកសារផ្សេងៗដែលពាក់ពន្ធ័ ហើយជាចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនដល់ឯកឧត្តម លោក លោកស្រីទាំងអស់ ដែលបានជួយបណ្តុះបណ្តាល និងជ្រោមជ្រែងយើងខ្ញុំទាំងអស់គ្នា តាំងពីដើមរហូតមក អោយជួបប្រទះនឹងពុទ្ធពរជ័យទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈកុំបីឃ្លាតឡើយ ។

# អារម្ភកថា

នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាជាប្រទេសកំពុងតែអភិវឌ្ឍន៍លើគ្រប់វិស័យជាពិសេស វិស័យធនាគារ និងហិរញ្ញវត្ថុ ដែលកំពុងតែមានភាពរីកចម្រើនគួរអោយកត់សំគាល់។ ទន្ទឹមនឹងការកើន ឡើងនូវធនាគារដ៏ច្រើននោះ ការរីកចំរើននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏មានការកើនឡើងផងដែរតាមរយៈការផ្តល់នូវសេវាមួយចំនួន ជាពិសេសសេវាឥណទានដែលមួយភាគធំត្រូវបានផ្តល់ទៅដល់ ប្រជាជននៅតាមទីជនបទដែលត្រូវការជំនួយ។

អាស្រ័យហេតុនេះហើយ បានជំរុញអោយយើងខ្ញុំមានសេចក្តីសោមនស្សក្នុងការលើកយកប្រធានបទ "**ការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់**" កមធ្វើការចងក្រងឡើងដើម្បីដោះស្រាយ នូវ ចំងល់ទាំងនោះ និងសិក្សាបន្ថែមទៅលើបញ្ហាដែលទាក់ទងទៅនឹងប្រធានបទដោយធ្វើឡើងស្ថិត ក្រោមការដឹកនាំរបស់លោកសាស្ត្រាចារ្យ ***សូវ វេងនី*** និងការចុះកម្មសិក្សាផ្ទាល់នៅធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ដែលបានជួយជំរុញឆ្ពោះទៅរកភាពជោគជ័យនៃការរៀបចំរបាយការណ៍នេះឡើង។

ជាការពិតណាស់ ថ្វីត្បិតតែសៀវភៅនេះគ្រាន់តែជាសមិទ្ធផលដ៏តូចប៉ុន្តែយើងសង្ឃឹមថា និងជាបទពិសោធន៍មួយក្នុងការអភិវឌ្ឍទៅលើរបាយ ការណ៍ កម្មសិក្សានេះនឹងផ្តល់សារៈសំខាន់ការសិក្សា ចំពោះយើងខ្ញុំផ្ទាល់ និងសំរាប់ទុកជាឯកសារដល់មិត្តនិស្សិតជំនាន់ក្រោយទៀត ជាពិសេសសិស្ស និស្សិតដែលមានចំងល់ និងចង់ស្រាវជ្រាវពីវិស័យធនាគារដើម្បីទទួលបានចំនេះដឹងមួយផ្នែកពី សៀវភៅនេះ។

យើងខ្ញុំសូមអភ័យទោសចំពោះរាល់កំហុសខុសឆ្គងដែលកើតមានឡើងក្នុងការ ជាទីបញ្ចប់បង្កើតនូវសៀវភៅនេះឡើង ហើយយើងខ្ញុំនឹងរងចាំទទួលនូវក ារិះគន់ក្នុងន័យស្ថាបនាពីសំណាក់លើកសាស្ត្រចារ្យ និងបណ្តាមិត្តទាំងអស់នូវរាល់ចំនុចខ្វះខាតដែលកើតមានឡើងដោយអចេតនា។

## មាតិកា

បញ្ជីតារាង ........ vii
បញ្ជីអក្សរកាត់........ viii
បញ្ជីឧបសម្ពន្ធ័........ ix

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ........ ១
២.ចំណោទបញ្ហា ........ ២
៣.គោលបំណងនៃការស្រាវជ្រាវ........ ២
៤.វីធីសាស្រ្តនៃការស្រាវជ្រាវ........ ៣
៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៦.សារៈសំខាន់នៃការស្រាវជ្រាវ........ ៤
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........ ៤

## ជំពូកទី១
## ការរំលឹកទ្រឹស្តីជុំវិញការផ្តល់ឥណទាន

១.១. និយមន័យធនាគារ........ ៦
១.២. ប្រវត្តិនៃការកកើតធនាគារ ........ ៦
១.៣. តួនាទីរបស់ធនាគារ........ ៧
១.៣.១. តួនាទីអន្តរការី ........ ៧
១.៣.១. តួនាទីអន្តរការី ........ ៧
១.៣.៣. តួនាទីជាអ្នកធានា ........ ៨
១.៣.៤. តួនាទីជាអ្នកគ្រប់គ្រងហានិភ័យ........ ៨
១.៣.៥. តួនាទីជាធនាគារវិនិយោគ........ ៨
១.៣.៦. តួនាទីជាអ្នកប្រឹក្សាយោបល់លើការសន្សំ និងការវិនិយោគ ........ ៨
១.៣.៧. តួនាទីជាអ្នករក្សាវត្ថុមានតំលៃ........ ៩
១.៣.៨. តួនាទីជាភ្នាក់ងារ ........ ៩
១.៣.៩. តួនាទីជាអ្នកអនុវត្តគោលនយោបាយ........ ៩
១.៤. លក្ខណៈទូទៅនៃឥណទា ........ ៩

១.៤.១. និយមន័យឥណទាន........................................................................ ៩
១.៤.២. អត្ថប្រយោជន៍នៃកម្ចី ...................................................................... ១០
១.៤.៣ .ការចាត់ថ្នាក់ឥណទាន ..................................................................... ១១
១.៤.៣.១.ឥណទានសាធារណជន ............................................................ ១២
១.៤.៣.២.ឥណទានឯកជន....................................................................... ១២
១.៤.៤.ប្រភេទឥណទាន .............................................................................. ១២
១.៥.លក្ខខណ្ឌក្នុងការផ្តល់ឥណទាន .............................................................. ១៣
១.៥.១. ការវិភាគលើ៤R ............................................................................ ១៣
១.៥.២.ការវិភាគលើ៥C ............................................................................. ១៥
១.៥.៣. ដំណើរការនៃការផ្តល់ឥណទាន ........................................................ ១៦
១៥.៤. ការត្រួតពិនិត្យឥណទានឡើងវិញ......................................................... ១៧
១.៦.ការគណនាការប្រាក់ ............................................................................. ១៨
១.៦.១. ការប្រាក់ទោល ឬការប្រាក់សាមញ្ញ ................................................... ១៩
១.៦.២. ការប្រាក់ផ្គួប ឬការប្រាក់សមាស ....................................................... ២០
១.៧.របៀបសងប្រាក់ ..................................................................................... ២០
១.៧.១. ការសងតែការប្រាក់ ........................................................................... ២០
១.៧.២. សំណងដោយរំលោះតាមលំដាប់ចុះ ................................................... ២០
១.៧.៣. វិធីសាស្រ្តសំណងប្រចាំគ្រាថេរ............................................................. ២១
១.៨. ហានិភ័យឥណទាន.................................................................................. ២១
១.៨.១.និយមន័យហានិភ័យឥណទាន ............................................................ ២១
១.៨.២. មូលហេតុដែលបណ្តាលមានហានិភ័យ.................................................. ២១
១.៩.ការគ្រប់គ្រងហានិភ័យឥណទាន ............................................................... ២១
១.៩.១. ការត្រួតពិនិត្យបំណុល......................................................................... ២១
១.៩.២. បំណុលមានបញ្ហានិងដំណោះស្រាយ ..................................................... ២២
ជំពូកទី២ ស្ថានភាពទូទៅរបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់
២.១. ប្រវត្តិរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់..................................................... ២៤
២.២. គោលបំណង និងអត្ថប្រយោជន៍.............................................................. ២៥
២.៣. ភាគទុនិករបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ............................................ ២៦

២.៤. ផ្លាកសញ្ញា និងអត្ថន័យ ........................................................................ ២៧
២.៥. ចក្ខុវិស័យ បេសកកម្ម និងគុណតំលៃរបស់ធនាគារ ................................................ ២៩
២.៦. រចនាសម្ពន្ធ័ចាត់តាំងរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់សាខាស្ទឹងមានជ័យ ..................... ៣០
២.៧. ផលិតផល និងសេវាកម្មរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ......................................... ៣០
២.៧.១. ប្រភេទគណនីសន្សំ ................................................................ ៣០
២.៧.២. ការផ្តល់ប្រាក់កម្ចី ឬឥណទាន ...................................................... ៣១
២.៧.៣. សេវាផ្ទេរប្រាក់ ..................................................................... ៣២
២.៧.៤. លិខិតធានារបស់ធនាគារ ........................................................... ៣៣
២.៧.៥. ហិរញ្ញប្បទានពាណិជ្ជកម្ម ........................................................... ៣៣
២.៧.៦. ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន .................................................... ៣៤
២.៧.៧. សេវាបើកប្រាក់បៀវត្សន៍ ............................................................ ៣៤
២.៨. វប្បធម៌ការងាររបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ................................................. ៣៥
២.៨.១. ពេលម៉ោងបំរើការងារ .............................................................. ៣៥
២.៨.២. សុជីវធម៌ និងចរិយាមាយាទ ......................................................... ៣៥
២.៨.៣. ឥរិយាបទនៅកន្លែងធ្វើការងារ ....................................................... ៣៦
២.៨.៤. ការប្រាស្រ័យទាក់ទង និងការបង្គាប់បញ្ជា .......................................... ៣៦

**ជំពូកទី៣ ការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់**

៣.១. លក្ខណៈទូទៅឥណទាន ................................................................ ៣៨
៣.៣.១. និយមន័យឥណទាន ................................................................ ៣៨
៣.២. ការចាត់ថ្នាក់ឥណទាន ................................................................... ៣៨
៣.៣. ប្រភេទឥណទាន ........................................................................ ៣៩
៣.៤. លក្ខខណ្ឌក្នុងការផ្តល់ឥណទាន .......................................................... ៤០
៣.៤.១. ការវិភាគលើ៤Rs ................................................................... ៤០
៣.៤.២. ការវិភាគលើ៥Cs ................................................................... ៤១
៣.៤.៣. ដំណើរការនៃការផ្តល់ឥណទាន ..................................................... ៤២
៣.៤.៤. ទ្រព្យធានាដែលអាចទទួលយកបាន ................................................. ៤៤
៣.៥. ការគណនាអត្រាការប្រាក់ ............................................................... ៤៦
៣.៦. របៀបសងប្រាក់ ........................................................................ ៤៦

៣.៧. ហានិភ័យឥណទាន និងមូលហេតុបណ្តាលឲ្យមានហានិភ័យ.................................. ៤៧
៣.៧.១. ហានិភ័យឥណទាន.................................................................................. ៤៧
៣.៧.២. មូលហេតុបណ្តាលឲ្យមានហានិភ័យ ........................................................ ៤៧
៣.៨. ការគ្រប់គ្រងហានិភ័យឥណទាន ......................................................................... ៤៩
៣.៨.១. ការត្រួតពិនិត្យឥណទានឡើងវិញ ............................................................ ៤៩
៣.៨.២. ឥណទានមានបញ្ហានិងដំណោះស្រាយ ...................................................... ៤៩

**ជំពូកទី៤ ការពិភាក្សាលើការស្ទង់មតរបស់អតថជន និងការវាយតំលៃទៅលើ ការផ្តល់ឥណទានរបស់ធនាគារវឌ្ឍន: អាស៊ីចំកាត់**

៤.១. ការពិភាក្សាទៅលើមតិរបស់អតិថជន ................................................................. ៥១
៤.១.១. ការស្ទាបស្ទង់មតិយោបល់របស់អតិថជនលើធនាគារទូទៅ............................ ៥១
៤.១.២. ការស្ទាបស្ទង់មតិយោបល់របស់អតិថជនលើធនាគារវឌ្ឍន:អាស៊ីចំកាត់......... ៥២
៤.២. ការវាយតម្លៃ និងវិភាគលើធានាគារវឌ្ឍន: អាស៊ីចំកាត់ ............................................ ៥៤
៤.២.១. ការវាយតម្លៃលើធានាគារវឌ្ឍន: អាស៊ីចំកាត់................................................ ៥៤
៤.២.២. ចំណុចខ្លាំង................................................................................................ ៥៥
៤.២.៣. ចំនុចខ្សោយ................................................................................................ ៥៦

**សេចក្តសន្និដ្ឋាន និង ការផ្តល់អនុសាសន៍**

១. សេចក្តីសន្និដ្ឋាន.................................................................................................. ៥៧
២.ការផ្តល់អនុសាសន៍ ................................................................................................ ៥៨

**ឧបសម្ព័ន**

**ឯកសារយោង**

បញ្ជីតារាង

តារាងទី១ : ប្រាក់កម្ចីធៀបនឹង ទ្រព្យធានា ........................................................... ៤៥
តារាងទី២ : ចំនួនទឹកប្រាក់កម្ចី ........................................................... ៤៥
តារាងទី៣ : ប្រភេទនៃឥណទាន ........................................................... ៤៦
តារាងទី៤ : ការគណនាការប្រាក់ ........................................................... ៤៦

# បញ្ជីអក្សរកាត់

CBC : Credit Bureau Cambidia

CCMBL : Credit Committee Micro Business Loan

CAR : Credit Analysis Report

MBLO : Micro Business Loan Officer

HO : Heand Office

EMP : Equal Monthly Principal

EMI : Equal Monthly Interest

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ កិច្ចសន្យា

ឧបសម្ព័ន្ធទី២ ៖ តារាងបង់ប្រាក់

ឧបសម្ព័ន្ធទី៣ ៖ កម្រងសំនួរ

ឧបសម្ព័ន្ធ៤ ៖ ក្រាបបង្ហាញពីការស្ទង់មតិរបស់អតិថជន

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការលើកស្ទួយជីវភាពប្រជាជន ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ច ជាតិមានការរីកចម្រើនជាលំដាប់។ ជារួម ពោលគឺមានការអភិវឌ្ឍស្ទើរតែគ្រប់ វិស័យដែលមានដូចជា វិស័យពាណិជ្ជកម្ម ឧស្សាហាកម្ម កសិកម្ម ទេសចរណ៍។ល។ សុទ្ធតែមានការរីកចម្រើនលូតលាស់គួរអោយ កត់សម្គាល់។ ដោយអនុវត្តតាមគោលនយោបាយ សេដ្ឋកិច្ចទីផ្សារសេរី បានបើកទ្វារទទួលអោយមាន អ្នកវិនិយោគគ្រប់ប្រភេទមកបណ្តាក់ទុនស្ទើរតែគ្រប់វិស័យទាំងអស់។ ម្យ៉ាងវិញទៀត យើងបានបង្កើត អោយមានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជាដៃគូជាច្រើន ដែលជាសមាជិក WTO ក៏ដូចជាមានទំនាក់ទំនងរវាងសហគ្រាស ឬក្រុមហ៊ុននៅក្នុងស្រុកផងដែរ។ ដោយសារតែកត្តាទាំងនេះបាន បង្កើតអោយមានធនាគារ និងបានជួយសម្រួលដល់អ្នកវិនិយោគ ក៏ដូចជាប្រជាជនទូទៅទាំងក្នុង និង ក្រៅប្រទេស ដោយសារតែពួកគេសុទ្ធតែត្រូវការធនាគារជាដៃគូសម្រួលក្នុងជីវភាពប្រចាំថ្ងៃ និងការធ្វើ អាជីវកម្ម។ ពេលខ្លះធនាគារបានជួយជ្រោមជ្រែងនូវបណ្តាវិនិយោគិន ពេលដែលពួកគេត្រូវការ មូលធនបន្ថែមទុកសម្រាប់ពង្រីកអាជីវកម្មរបស់ពួកគេ និងធ្វើការប្រកួតប្រជែងនៅលើទីផ្សារ។ ឥណទានមិនបានធានាអោយអាជីវកម្មនោះមានដំណើរការទាំងស្រុងទេ ប៉ុន្តែវាបានជួយផ្តល់ឱកាសដល់ អាជីវកម្មថ្មី ក៏ដូចជាអាជីវកម្មដែលបន្តពីមុនអោយកាន់តែរលូន និងការជម្រុញអោយមានការឈាន ចូលទីផ្សារដែលទទួលស្គាល់។ ជាពិសេសឥណទានបានបំពេញសេចក្តីត្រូវការទូទៅរបស់ប្រជាជន គ្រប់ស្រទាប់វណ្ណៈ។ ទន្ទឹមនឹងនេះធនាគារក៏បានទទួលផលប្រយោជន៍មកវិញផងដែរនូវចំណូលយ៉ាង ច្រើន។ ឥណទានជាផលិតផលចាំបាច់ក្នុងការស្វែងរកប្រាក់ចំណូលនោះទើបគ្រប់ធនាគារពាណិជ្ជ បានរៀបចំនូវយុទ្ធសាស្ត្រអោយមានប្រសិទ្ធភាព ដើម្បីទាក់ទាញអតិថិជនឲ្យមកប្រើប្រាស់សេវាឥណទានរបស់ខ្លួន។ ក៏ប៉ុន្តែ វាមិនមានជាការងាយស្រួលនោះទេក្នុងការទាក់ទាញ និងធ្វើឲ្យដំណើរការឥណទានមួយមិនមានបញ្ហា ឬការកាត់បន្ថយហានិភ័យដែលមាននៅក្នុងឥណទាននីមួយៗឲ្យស្ថិតក្នុង កម្រិតទាបបំផុត។

ការវិនិយោគមានការកើនឡើងបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជាជារៀងរាល់ថ្ងៃ ស្របពេលដែល សន្ទុះសេដ្ឋកិច្ចរបស់កម្ពុជាកើនឡើងផងដែរ។ ការវិនិយោគទាំងនោះមិនប្រាកដថាសុទ្ធតែប្រើប្រាស់ ដើមទុនផ្ទាល់ខ្លួនរបស់វិនិយោគិនតែមួយផ្លូវប៉ុណ្ណោះទេ តែវាក៏ត្រូវការកម្លាំងបន្ថែមពីខាងក្រៅផងដែរ ដូចជាស្វែងរកទុនបន្ថែមពីការលក់ដូរភាគហ៊ុន ឬប័ណ្ណបំណុល ហើយម៉្យាងវិញទៀតប្រភពដែលអាច ផ្តល់ទុនដល់វិនិយោគិនងាយស្រួលជាង និងពេញនិយមជាងប្រភពទាំងពីរខាងលើនៅក្នុងប្រទេសកម្ពុ-ជា គឺ ឥណទានអាជីវកម្មរបស់ធនាគារ។ ធនាគារជាគ្រឹះស្ថានហិរញ្ញវត្ថុដែលដើរតួនាទីសំខាន់នៅក្នុង ប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងប្រទេសមួយនេះ។ យ៉ាងណាមិញប្រទេសកម្ពុជាមានធនាគារពាណិជ្ជ ជាច្រើនដែលកំពុងតែធ្វើប្រតិបត្តិការរបស់ខ្លួននៅក្នុងវិស័យហិរញ្ញវត្ថុ។ ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ជាធនាគារពាណិជ្ជមួយដែលបានឈានជើងចូលមកក្នុងវិស័យហិរញ្ញវត្ថុកម្ពុជាអស់រយៈពេល២០ឆ្នាំមកហើយ យើងសង្កេតឃើញថាធនាគារនេះគឺផ្តោតទៅលើសកម្មភាពអាជីវកម្ម ពោលគឺការវិនិយោគ ។

ការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ គឺជាប្រធានបទមួយដែលសក្តិ- សមនឹងជ្រើសយកមកធ្វើការស្រាវជ្រាវបំផុតសម្រាប់កាលៈទេសៈនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីសិក្សាអោយកាន់តែច្បាស់ពីចរិតលក្ខណៈនៃការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ ក្រុមយើងខ្ញុំសម្រេចកំនត់នូវចំណោទបញ្ហាដូចខាងក្រោម៖

- តើមានវិធីសាស្ត្រអ្វីខ្លះដែលធនាគារវឌ្ឍនៈ អាស៊ីចំកាត់ប្រើប្រាស់ក្នុងការផ្តល់ឥណទាន?
- តើធនាគារវឌ្ឍនៈអាស៊ីចំកាត់ មានចំណុចខ្លាំង និងខ្សោយអ្វីខ្លះ លើការផ្តល់ឥណទាន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំមានគោលបំណងចង់ពង្រីកចំនេះដឹង ដែលបានសិក្សាកន្លងមក ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងបទពិសោធន៍បន្ថែម ក៏ដូចជាឆ្លើយតបជាមួយនឹងចំណោទបញ្ហាខាង លើនិងចងក្រងជាសៀវភៅទុកនៅក្នុងបណ្ណាល័យសម្រាប់អោយនិស្សិតជំនាន់ក្រោយទៀត និងអ្នក ដែលមានបំណងចង់ដឹងព័ត៌មានដែលទាក់ទងនឹងធនាគារ វឌ្ឍនៈ អាស៊ីចំកាត់។

ក្រុមយើងខ្ញុំបានសិក្សាផ្តោតលើចំណុចសំខាន់មួយចំនួនដូចជា៖

- ទិដ្ឋភាពទូទៅស្តីពីការផ្តល់ឥណទាន
- ស្ថានភាពទូទៅរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់
- ភាពជាក់ស្តែងនៃការផ្តល់ឥណទានអាជីវកម្មនៅធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ មានដូចជា ៖
    - លក្ខណៈពិសេសនៃការផ្តល់ឥណទាន
    - ការផ្សព្វផ្សាយពីឥណទាន
    - នីតិវិធីនៃការផ្តល់ឥណទាន
    - ប្រសិទ្ធភាពនៃយុទ្ធសាស្ត្ររបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ ចំពោះឥណទានអាជីវកម្ម ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារតែធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ជាធនាគារមួយដែលកំពុងមានការអភិវឌ្ឍហើយបានធ្វើការពង្រីកសាខាជាច្រើននៅតាមតំបន់មួយចំនួនរីឯលទ្ធភាពនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនៅមានកម្រិតនោះនាំអោយការសិក្សាស្រាវជ្រាវនេះមិនអាចផ្តោតទៅលើគ្រប់ស្ថាប័នទាំងអស់នោះទេ។

ដូចនេះ ហើយការស្រាចជ្រាវបានផ្តោតសំខាន់ តែលើការផ្តល់ឥណទានរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ សាខាស្ទឹងមានជ័យ និងវិភាគទិន្នន័យពីឆ្នាំ ២០១៦ និង ២០១៧ តែប៉ុណ្ណោះ។ ចំពោះ ទិន្នន័យនិងឯកសារផ្សេងទៀត យើងក៏ទទួលបានត្រឹមតែក្នុងសាខានេះដែរ ហើយនឹងការសាកសួរ ព័ត៌មានបន្ថែម ពីសំនាក់ប្រធានសាខា និងបណ្តាបុគ្គលិកដែលពាក់ព័ន្ធ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីអោយបញ្ចប់បានជោគជ័យនូវការស្រាវជ្រាវលើប្រធានបទ ការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ សាខាស្ទឹងមានជ័យ យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រសំខាន់ដូចខាងក្រោម

- ទិន្នន័យចំបង

ទិន្នន័យចំបងប្រភេទនេះ គឺយកបានតាមរយៈការប្រមូលដូចជា៖

- ការចុះកម្មសិក្សាផ្ទាល់នៅធនាគារធនាគារវឌ្ឍនៈ អាស៊ីចំកាត់ សាខាស្ទឹងមានជ័យ

- បទសម្ភាសន៍ ឬការសាកសួរផ្ទាល់ពីបុគ្គលិករបស់ធនាគារ ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ សាខាស្ទឹងមានជ័យធ្វើការប្រមូលទិន្នន័យ និងឯកសារសំខាន់ដែលពាក់ព័ន្ធ។

➢ ទិន្នន័យបន្ទាប់បន្សំ

ចំពោះទិន្នន័យបន្ទាប់បន្សំ គឺយកបានតាមរយៈការប្រមូលដូចជា៖

- សៀវភៅដែលទាក់ទង
- អ៊ីនធើណែត
- មេរៀនដែលបានសិក្សាពីសាស្ត្រាចារ្យកន្លងមក
- របាយការណ៍សិក្សាស្រាវជ្រាវ និងកម្មសិក្សារបស់និស្សិតជំនាន់មុន។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានផ្តល់នូវសារៈសំខាន់ដល់យើងខ្ញុំដូចជា៖

- ទទួលបានបទពិសោធន៍ជាក់ស្តែងទាក់ទងនឹងការផ្តល់ឥណទាន
- យល់ដឹងពីសកម្មភាពគ្រប់គ្រងឥណទានរបស់ធនាគារ ធនាគារវឌ្ឍនៈ អាស៊ីចំកាត់
- យល់ដឹងពីអត្ថប្រយោជន៍ដែលបានពីការប្រើប្រាស់ឥណទាន
- អាចទុកជាឯកសារសម្រាប់និស្សិត និងអ្នកស្រាវជ្រាវជំនាន់ក្រោយ
- ជាមូលដ្ឋានសម្រាប់សិក្សាបន្តកម្រិតក្រោយឧត្តមសិក្សា

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានបែងចែកជា៖

➢ សេចក្តីផ្តើម

➢ ជំពូកទី១ ៖ រំលឹកទ្រឹស្តីនៃការផ្តល់ឥណទាន

➢ ជំពូកទី២ ៖ ស្ថានភាពទូទៅរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់

➢ ជំពូកទី៣ ៖ ការផ្តល់ឥណទានរបស់ធនាគារ ធនាគារវឌ្ឍនៈ អាស៊ីចំកាត់

➢ ជំពូកទី៤ ៖ កាពិភាក្សាការស្ទង់មតិរបស់អតិថជន និងការវាយតំលៃលើការផ្តល់ឥណទាន

➢ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

**បញ្ហា**

**រំលឹកទ្រឹស្តី**

- និយមន័របស់ធនាគារ
- ប្រវត្តិនៃការកកើតធនាគារ
- តួនាទីរបស់ធនាគាពាណិជ្ជ
- លក្ខណៈទូទៅនៃឥណទាន
- ការចាត់ថ្នាក់ឥណទាន
- ការវិភាគលើ៤Rs
- ការវិភាគលើ៦Cs
- ដំណើរការក្នុងការផ្តល់ឥណទាន
- របៀបគណនាការប្រាក់
- របៀបសងប្រាក់
- ហានិភ័យឥណទាន

**ជំពូកទី២**

- ប្រវត្តិ និង ស្ថានភាពធនាគារ វឌ្ឍនៈ អាស៊ីចំកាត់
- ទស្សនៈវិស័យ បេសកម្ម និងគោលបំណង
- ផលិតផល និងសេវាកម្ម
- វប្បធម៌ការងាររបស់ធនាគារ

**ជំពូកទី៣**

- លក្ខណៈទូទៅនៃឥណទាន
- ការចាត់ថ្នាក់ឥណទាន
- ការវិភាគលើ៤Rs
- ការវិភាគលើ៥Cs
- ដំណើរការក្នុងការផ្តល់ឥណទាន
- ការគណនាការប្រាក់
- របៀបសងប្រាក់
- ហានិភ័យឥណទាន

**ជំពូកទី៤**

- ការពិភាគក្សាទៅលើមតិអតិថជន
- ការវាយតម្លៃនិងការវិភាគលើធនាគារ វឌ្ឍនៈ អាស៊ីចំកាត់

**ចំនុចខ្លាំង និង ចំនុចខ្សោយ**

- ចំពោះគ្រឹះស្ថានទូទៅ
- ចំពោះធនាគារវឌ្ឍនៈ អាស៊ីចំកាត់

**សេចក្តីសន្និដ្ឋាន**
**និងការផ្តល់អនុសាសន៍**

# ជំពូកទី ១
# រំលឹកទ្រឹស្តីនៃការផ្តល់ឥណទាន

# ជំពូកទី១
# រំលឹកទ្រឹស្តីនៃការផ្តល់ឥណទាន

## ១.១ និយមន័យធនាគារ

ជាទូទៅធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុច្រើនប្រភេទដូចជា ទទួលប្រាក់បញ្ញើដែលគ្មានមុខសញ្ញាប្រើប្រាស់ និងប្រាក់សន្សំពីសាធារណជនផ្តល់ឥណទានអោយឯកត្តជន និងក្រុមហ៊ុនអាជីវកម្មជំនួញដោយយកការប្រាក់ព្រមទាំងផ្តល់សេវាលើការងារទូទាត់ និងធ្វើវិនិយោគក្រោមរូបភាពជា សញ្ញាប័ណ្ណ និងមូលបត្រមានតំលៃដើម្បីស្វែងរកប្រាក់ចំណេញសម្រាប់ម្ចាស់ក្រុមហ៊ុន។[1]

ធនាគារគឺជាស្ថាប័ន ឫគ្រឹះស្ថានសំរាប់ទូទាត់ប្រាក់បញ្ញើ ឫបណ្តាក់ទុនជាបណ្តាញប្រមូលប្រាក់សន្សំដែលឥតប្រើប្រាស់ ឫដែលនៅទំនេរនៅក្នុងសេដ្ឋកិច្ច យកទៅចែកចាយនៅតាមគ្រប់វិស័យសេដ្ឋកិច្ច តាមការអោយឥណទានដើម្បីលើកស្ទួយសកម្មភាព និងអភិវឌ្ឍន៍សង្គម។[2]

ក្រោមច្បាប់របស់ប្រទេសកម្ពុជា ធនាគារគឺជានិតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី។ ហើយប្រតិបត្តិការដែលជាសកម្មភាពធនាគាររួមមាន៖

- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ដោយមានកម្រៃរាប់បញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខា
- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន
- ការដាក់អោយអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឫជារូបប័ណ្ណ។

## ១.២ ប្រវត្តិនៃការកកើតរបស់ធនាគារ

ប្រវត្តិនៃការបង្កើតធនាគារ គឺផ្សារភ្ជាប់ជាមួយនឹងប្រវត្តិនៃការរីកចម្រើនវិស័យផលិតកម្ម ។ ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច គឺជាលក្ខខណ្ឌ និងការទាមទារនូវការអភិវឌ្ឍ របស់ធនាគាររហូតមកដល់ បច្ចុប្បន្ននេះ ការអភិវឌ្ឍប្រព័ន្ធធនាគារបានជម្រុញអោយមានការអភិវឌ្ឍសេដ្ឋកិច្ច។

ធនាគារចាប់ផ្តើមកើតឡើងតាមរយៈមុខងារប្តូរប្រាក់របស់ជាងមាស។ ចំពោះការចរាចរប្រាក់នៅក្នុងប្រទេសនីមួយៗ និងក្នុងតំបន់នីមួយៗ ជាពិសេសចំពោះពាណិជ្ជកម្មអន្តរជាតិទាមទារអោយ មានការប្តូរប្រាក់នៅតាមច្រកព្រំដែន ដើម្បីងាយស្រួលក្នុងការទិញ លក់ទំនិញ។[3]

[1] www.academia.edu/31513027

[2] ហាក់ ស្រីខៀន និង ឆេង ភីរុណ, "ការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្មរបស់ធនាគារ អេស៊ីលីដា", ២០១២ ទំព័រ ៥

ដូចនេះត្រូវបង្កើតនូវហាងប្តូរប្រាក់ ដើម្បីធ្វើការដោះដូរនូវរូបបិយប័ណ្ណរបស់ប្រទេសមួយជាមួយនិងរូបបិយប័ណ្ណរបស់ប្រទេសមួយទៀត។ ចំពោះអ្នកដែលរកស៊ីដែលរកស៊ីប្តូរប្រាក់នេះភាគច្រើនជាអ្នកមាន និងពីមុនអាចជាអ្នកផ្តល់កម្ចីដោយយកការប្រាក់ខ្ពស់ រឺរក្សាលុយទុកឲ្យអ្នកធ្វើអាជីវកម្មមាស និងតួនាទីផ្សេងៗ។ ដូចនេះអ្នករកស៊ីប្តូរប្រាក់បានបង្កើតមុខងាមួយទៀត គឺរក្សាលុយទុកឲ្យ។ ដូចនេះពួកគេកាន់តែមានចំណូលខ្ពស់ថែមទៀត និងម្យ៉ាងទៀតការរក្សាលុយកាន់តែច្រើនឡើងៗ ធ្វើឲ្យមានការទូទាត់ថ្លៃទំនិញជំនួសទៀត ឬការទូទាត់មិនប្រើសាច់ប្រាក់។ តាមរយៈការទូទាត់មិនប្រើសាច់ប្រាក់នេះ កាន់តែច្រើនថែមទៀត។

## ១.៣ តួនាទីរបស់ធនាគារ

កាលពីអតីតកាល ធនាគារពាណិជ្ជមានមុខងារត្រឹមការទទួលប្រាក់បញ្ញើ និងផ្តល់កម្ចីតែប៉ុណ្ណោះ។ ប៉ុន្តែនាពេលបច្ចុប្បន្ន ធនាគារបានអភិវឌ្ឍន៍ និងបង្កើតនូវតួនាទីមួយចំនួនបន្ថែមទៀត ដើម្បី ប្រកួតប្រជែងជាមួយស្ថាប័នហិរញ្ញវត្ថុនានានៅក្នុងទីផ្សារ និងបំពេញទៅតាមតម្រូវការរបស់សាធារណជនគ្រប់ស្រទាប់។ តួនាទីសំខាន់ៗរបស់ធនាគាររួមមានដូចខាងក្រោម ៖[4]

### ១.៣.១ តួនាទីអន្តរការីយ (Intermediation role)

តាមរយៈធនាគារបានផ្ទេរពីប្រាក់សន្សំទៅជាដើមទុនសំរាប់វិនិយោគ ដោយភ្ជាប់ទំនាក់ទំនងរវាងភាគីពីរ រឺស្ថាប័នផ្សេងគ្នានៅក្នុងវិស័យសេដ្ឋកិច្ច។

### ១.៣.២ តួនាទីអន្តរការីយទូទាត់ (Payment role)

លុយ និងមាសមានមុខងារសំខាន់បំផុត គឺធ្វើជាមធ្យោបាយទូទាត់។ បណ្តាធនាគារបានបង្កើតឡើងមិនអាចបង្កើតបាននូវលុយលោហៈធាតុ ដូចនេះ បណ្តាធនាគារជាងមាសបានបង្កើតមធ្យោបាយទូទាត់ដោយបោះផ្សាយនូវក្រដាសបំណុល។ ក្រដាសបំណុលនេះបានក្លាយទៅឧបករណ៍ទូទាត់ដែលត្រូវបានអតិថិជនទទួលស្គាល់។ ដំបូងធនាគារបង្កើតក្រដាសបំណុលនោះឡើង ដើម្បីជំនួសអោយរូបិយវត្ថុលោហៈធាតុដែលកំពុងចរាចរ ប៉ុន្តែក្រោយមកក្រដាសបំណុលនេះក៏ត្រូវបានប្រើប្រាស់ជំនួសអោយរូបិយវត្ថុលោហៈធាតុទាំងស្រុង ដូចនេះក្រដាស់បំណុលនេះបានក្លាយទៅជាក្រដាសប្រាក់។

[3] សួន ចំរើន, ២០១៦, «រូបិយវត្ថុ និងធនាគារ», ទំព័រទី៧

[4] Peter S.R & Sylvia C.H; (2013), Book Management & Financial Service, 9th edition, Published by McGraw Hill, NY, Page 9

ចំពោះការបោះផ្សាយក្រដាសប្រាក់ គឺទទួលបានប្រាក់ចំនេញច្រើនណាស់។ ដោយសារតម្រូវការនូវក្រដាសប្រាក់នេះតំណាងដោយប្រទេសមួយ ដូចនេះការបោះផ្សាយក្រដាសប្រាក់នេះត្រូវផ្ទេរតួនាទីទៅអោយធនាគារកណ្តាលវិញ។ ចាប់តាំងពីពេលនោះមក បណ្តាលធនាគារពាណិជ្ជទាំងអស់ត្រូវបញ្ឈប់ការបោះផ្សាយនូវក្រដាសប្រាក់សំរាប់ខ្លួន។[5]

**១.៣.៣ តួនាទីជាអ្នកធានា** ( Guarantor role )

ចំពោះតួនាទីនេះ ធនាគារជាអ្នកធានាដល់ភាគីទី ៣ ណាមួយអំពីលទ្ធភាពទូទាត់បំណុលរបស់អតិថិជនរបស់ខ្លួនដោយធនាគារអាចចេញនូវលិខិតឥណទាន (Letter of Credit) ជាដើម។ ធនាគារអាចធានាថា អតិថិជនរបស់ខ្លួននឹងមានលទ្ធភាពសងបំណុលដល់ភាគីទី ៣ នោះ។ ក្នុងករណីដែរអតិថិជននោះគ្មានលទ្ធភាពសងទេ នោះធានាគារនឹងចេញមុខទទួលខុសត្រូវលើបំណុលនោះ។[6]

**១.៣.៤ តួនាទីជាអ្នកគ្រប់គ្រងហានិភ័យ** ( Risk Management Role )

ធនាគារជួយអតិថិជនរបស់ខ្លួនដើម្បីរៀបចំលើការគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុ ដោយធនាគារធ្វើការទាក់ទង និងការផ្តល់យោបល់ទាក់ទងនឹងកិច្ចសន្យា ក្នុងគោលបំណងជៀសវាងនិងកាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតឡើង ដូចជាការបាត់បង់នូវទ្រព្យសម្បត្តិ និងជីវិតមនុស្ស។

**១.៣.៥ តួនាទីជាធនាគារវិនិយោគ** ( Investment Bank Role )

ក្នុងនាមជាធនាគារវិនិយោគ ធនាគារពាណិជ្ជបានដើរតួនាទីជាជំនួយការដល់ក្រុមហ៊ុនសាជីវកម្ម ក៏ដូចជារដ្ឋាភិបាលក្នុងការបង្កើតមូលធនថ្មីតាមរយៈមុខងារធានាទិញមូលបត្រ ដោយរៀបចំឯកសារអោយក្រុមហ៊ុនដើម្បីស្នើរសុំបោះផ្សាយមូលបត្រលក់ជាសាធារណៈលើកដំបូង និងជាព័ត៌មានសំរាប់អ្នកវិនិយោគដែលមានចំណាប់អារម្មណ៍ក្នុងការជួញដូរមូលបត្រ។ ផ្តល់ទីប្រឹក្សាយោបល់ដល់ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយមូលបត្រស្តីពី ប្រភេទ ចំនួន ថ្លៃ និងពេលវេលាសមស្របក្នុងការបោះផ្សាយមូលបត្រ។

**១.៣.៦ តួនាទីជាអ្នកប្រឹក្សាយោបល់លើការសន្សំនិងការវិនិយោគ**( Saving/Investment Advisor Role )

ធនាគារពាណិជ្ជអាជជួយអតិថិជនអោយសម្រេចបាននូវគោលបំណងក្នុងជីវិតរបស់ពួកគេតាមរយៈការផ្តល់យោបល់ទាក់ទិននឹងការប្រើប្រាស់ និងការគ្រប់គ្រងសាច់ប្រាក់អោយមាន

[5] សួន ចំរើន, ២០១៦, «រូបិយវត្ថុ និងធនាគារ», ទំព័រទី៩

[6] សេង សុខនីន, ២០១៦, «យុទ្ធសាស្ត្រនៃការផ្តល់ឥណទាន», ទំព័រទី១៣

ប្រសិទ្ធភាពសម្រាប់ផែនការអាជីវកម្មរបស់ពួកគេ និងជួយអតិថិជនរៀបចំផែនការសន្សំរយៈពេលវែង និងគំរោងសន្សំប្រាក់សោធននិវត្តន៍ ដើម្បីសំរេចបំណងប្រាថ្នារបស់អតិថិជននៅពេលចូលនិវត្តន៍។[7]

**១.៣.៧ តួនាទីជាអ្នករក្សាវត្ថុមានតំលៃ** ( Safekeeping/Certificate of Value Role )

ធនាគារពាណិជ្ជដើរតួនាទីជាអ្នករក្សានូវវត្ថុមានតំលៃជំនួសអោយអតិថិជន។ វត្ថុមានតំលៃទាំងនោះមានដូចជាមាស ពេជ្រ ប្លង់ដី ប្លង់ផ្ទះ និងវត្ថុមានតំលៃដ៏ទៃទៀត។ ជាងនេះទៅទៀតក្នុងករណីខ្លះ ប្រសិនបើអតិថិជនធ្វើការផ្ញើរមាស ( ដែលអាចធ្វើការចរាចរណ៍នៅលើទីផ្សារបាន ) នោះធនាគារក៏នឹងធ្វើការផ្តល់ជូនការប្រាក់ដល់អតិថិជនផងដែរ។[8]

**១.៣.៨ តួនាទីជាភ្នាក់ងារ** ( Agency Role )

ក្នុងនាមជាភ្នាក់ងារ ធនាគារដើរតួនាទីជំនួសអោយអតិថិជនរបស់ខ្លួនក្នុងការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរបស់ពួកគេ រួមមានកេរ្តិ៍មរតក បណ្តាំមរតកជាដើម។ តួនាទីនេះខុសពីតួនាទីជាអ្នករក្សាតំលៃត្រង់ថា ក្រោយពីការទទួលយល់ព្រមធ្វើជាអ្នកទទួលកេរ្តិ៍មរតកហើយធនាគារមានភារកិច្ចមួយទៀតគឺធ្វើការបែងចែកមរតក ជូនដល់អ្នកទទួលផលទៅតាមអ្វីដែលមាននៅក្នុងកិច្ចសន្យានៅពេលអតិថិជនទទួលមរណភាព។

**១.៣.៩ តួនាទីជាអ្នកអនុវត្តគោលនយោបាយ** ( Policy Role )

ក្រៅពីតួនាទីខាងលើ ធនាគារពាណិជ្ជក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល ដែរគោលនយោបាយទាំងនេះត្រូវបានចេញដោយធនាគារកណ្តាលរឺតនាគារជាតិក្នុងគោលបំណងគ្រប់គ្រងស្ថេរភាពថ្លៃ អតិផរណា និងកំណើនសេដ្ឋកិច្ចជាដើម។

## ១.៤ លក្ខណៈទូទៅនៃឥណទាន

### ១.៤.១ និយមន័យ

ឥណទានមានអត្ថន័យច្រើន ក្នុងនេះបានលើកយកន័យមួយចំនួនដែលមានជាប់ពាក់ព័ន្ធចំពោះការធ្វើប្រតិបត្តិការធនាគារ ទៅលើការប្រើប្រាស់ទុនទំនេររបស់ខ្លួន ឬបង្វិល។ ឥណទានមក ពីពាក្យ ឥណ+ទាន។ [9]

---

[7] ហួត ចរណៃ និង ម៉ក់ ទេវិទ្ធ, ២០១៣, "ការផ្តល់ឥណទានសម្រាប់ពង្រីកអាជីវកម្ម" ទំព័រទី១៣

[8] https://www.bom.mu/about-the-bank/role-and-functions-bank

[9] https://www.google.com/search?q=definition+of+loan&ie=utf-8&oe=utf-8&aq=t&rls=org.mozilla:en-US:official&client=firefox-a&channel=sb

- ឥណ: មានន័យថាការជំពាក់របស់នរណាម្នាក់ ឬបំណុល
- ទាន: មានន័យថាជាការផ្តល់ឬអោយបរិមាណទ្រព្យ (ចលនទ្រព្យ ឬអចលនទ្រព្យ)

ដូចនេះ ឥណទានមានន័យថាជាការផ្តល់នូវចលនទ្រព្យ និងអចលនទ្រព្យអោយអ្នកមានតម្រូវ ការលើទ្រព្យសម្បត្តិទាំងនោះពីសំនាក់អ្នកមានមូលនិធិជំពាក់។ ក្នុងន័យនេះ ក្រោយពីទទួលបាន ឥណទានរួចរាល់ហើយ អ្នកសុំខ្ចីត្រូវក្លាយជាអ្នកសងត្រលប់នូវទ្រព្យដែលបានខ្ចីក្រោយពីបានប្រើប្រាស់ចប់ ឬអនុវត្តទៅតាមកិច្ចព្រមព្រៀងដែលមានចែងនៅក្នុងកិច្ចសន្យា ហើយនឹងការកំនត់នូវពេល វេលាសងត្រលប់ជាក់លាក់ណាមួយ។ ហើយន័យមួយទៀតជាប្រភពធនធានហិរញ្ញវត្ថុដែលផ្តល់ ដោយធនាគារដល់អតិថិជន តាមរយៈការអោយខ្ចីដើម្បីយកទៅចាប់ផ្តើម ឬពង្រីក អាជីវកម្ម ឬផលិតផល ដោយសារឈរលើមូលដ្ឋានត្រូវសងត្រលប់មកធនាគារវិញ ទាំងប្រាក់ដើម និងការប្រាក់តាម កាលបរិច្ឆេទជាក់លាក់ដែលបានសន្យា។[10]

### ១.៤.២ អត្ថប្រយោជន៍នៃកម្ចី

ឥណទានមានអត្ថប្រយោជន៍ជាច្រើនដែលមានដូចជា៖

**ក. ចំពោះអ្នកប្រើប្រាស់**

ការរស់នៅរបស់មនុស្សធម្មតាទូទៅនាពេលបច្ចុប្បន្ន កំពុងបង្កើនតម្រូវការពីមួយថ្ងៃទៅមួយថ្ងៃ ដូចនេះហើយ មនុស្សទូទៅដែលជាអ្នកប្រើប្រាស់ កំពុងទទួលបានអត្ថប្រយោជន៍ពីការផ្តល់ឥណទាន សម្រាប់៖

- បង្កើនជីវភាពរស់នៅ៖ ជាទូទៅអ្នកប្រើប្រាស់ទទួលបាននូវអត្ថប្រយោជន៍ពីការប្រើ-ប្រាស់ឥណទាន ពីព្រោះគេអាចប្រើចំនូលនាពេលអនាគតសម្រាប់ការទូទាត់លើទំនិញ និងសេវាកម្ម។[11] នេះមានន័យថាអ្នកប្រើប្រាស់អាចបង្កើនជីវភាពរស់នៅបច្ចុប្បន្នរបស់ខ្លួនអោយល្អប្រសើរ ដោយផ្អែកលើសមត្ថភាពរកចំនូល ឬទទួលបានមូលនិធិពេលអនាគត។

[10] http://www.thefreedictionary.com/credit

[11] hYt cណៅ nig ម៉ក់ ទេវិទ្ធ, ២០១៣, "ការផ្តល់ឥណទានសម្រាប់ពង្រីអាជីវកម្ម" ទំព័រទី៩

- ដោះស្រាយភាពបន្ទាន់៖ អ្នកប្រើប្រាស់អាចទទួលមូលនិធិសម្រាប់ដោះស្រាយបន្ទាន់ និងវិបត្តិផ្សេងៗដោយប្រើប្រាស់នូវឥណទាន។
- ភាពងាយស្រួល៖ អ្នកប្រើប្រាស់អាចធ្វើដំណើរជុំវិញពិភពលោកដោយប្រើប័ណ្ណឥណទានសម្រាប់ការទូទាត់លើការចំណាយដូចជា សំបុត្រយន្តហោះ ថ្លៃសណ្ឋាគារជាដើម ដោយមិនចាំបាច់យកលុយតាមខ្លួនច្រើនទេ និងផ្តល់សុវត្ថិភាពផងដែរ។

**ខ. ចំពោះអាជីវកម្ម**

ដោយឡែកចំពោះអ្នកប្រកបអាជីវកម្មក៏ទទួលបាននូវផលចំនេញពីការទទួលបានប្រាក់កម្ចីនូវ៖

- ការពង្រីកទីផ្សារ៖ ការធ្វើអាជីវកម្មពឹងផ្អែកលើឥណទានដើម្បីពង្រីកទីផ្សារ និងស្វែងរកអតិថិជនដូចជា ការលក់ដោយជំពាក់ គឺដើម្បីប្រកួតប្រជែងនឹងតម្រូវការនៃឥណទានសម្រាប់ការរស់រាននៃអាជីវកម្ម។
- មូលនិធិហិរញ្ញវត្ថុ៖ អាជីវកម្មជាច្រើនត្រូវការទុន ដើម្បីចាប់ផ្តើមអាជីវកម្ម ដំនើរការ និង ពង្រីកប្រតិបត្តិការដូចជា ទីតាំងថ្មី សាខាថ្មី និយោជិកថ្មី និងចំនាយនៅលើទីផ្សារផ្សេងទៀត។

**គ. ចំពោះសេដ្ឋកិច្ច**

ឥណទានបានផ្តល់ផលចំនេញជាច្រើនដល់វិស័យសេដ្ឋកិច្ចដូចជា៖

- ឥណទានជាកត្តាជម្រុញអភិវឌ្ឍសេដ្ឋកិច្ច
- ជម្រុញអោយមានលំហូរសាច់ប្រាក់ និងកត្តាផលិតកម្មនៅក្នុងប្រព័ន្ធសេដ្ឋកិច្ច
- ធ្វើអោយមានភាពជឿជាក់ក្នុងការទូទាត់
- ធ្វើអោយមានស្ថិរភាពសេដ្ឋកិច្ច។

### ១.៤.៣ ការចាត់ថ្នាក់ឥណទាន

ប្រតិបត្តិការឥណទានកើតឡើងក្នុងទម្រង់បែបបទខុសៗគ្នាជាច្រើន។ ការចាត់ថ្នាក់នៃប្រភេទឥណទានផ្អែកទៅលើ គោលបំណងឥណទាន និងវិធីសាស្ត្រក្នុងការទូទាត់។ ឥណទានត្រូវបានចាត់ថ្នាក់ជាពីរក្រុមធំៗគឺ ឥណទានឯកជន(Private Credit)និងឥណទានសាធារណៈ (Public Credit)។

### ១.៤.៣.១ ឥណទានសាធារណៈ

ឥណទានសាធារណៈ គឺជាការខ្ចីដោយកម្រិតរដ្ឋាភិបាល ដើម្បីហិរញ្ញប្បទាន(Financing) ទិញទំនិញ សេវាកម្ម និងចំណាយលើកម្មវិធីសុខភាព ផ្តល់ជូនប្រជាពលរដ្ឋ។ រដ្ឋាភិបាលខ្ចីប្រាក់នៅពេលចំណូលបានមកពីពន្ធ ឬមិនមែនពន្ធ មិនគ្រប់គ្រាន់សម្រាប់ទូទាត់កម្មវិធីចំណាយសាធារណៈ។ ប្រាក់កម្ចីត្រូវបានប្រមូលតាមរយៈការលក់មូលលប័ត្របំណុលរបស់រាជរដ្ឋាភិបាល ដោយសន្យាសងមូលនិធិនេះទៅអ្នកវិនិយោគវិញ ជាមួយការប្រាក់តាមពេលវេលាកំណត់ប័ណ្ណ។[12]

### ១.៤.៣.២ ឥណទានឯកជន

ឥណទានឯកជន គឺជាឥណទានដែលបានប្រើដោយបុគ្គល ឬអង្គភាពអាជីវកម្ម ដើម្បីដោះដូរនៅក្នុងវិស័យឯកជននៃសេដ្ឋកិច្ចយើង។[13]

### ១.៤.៤ ប្រភេទឥណទាន

ដោយផ្អែកលើគោលបំណងឥណទានរបស់អតិថិជនឥណទានត្រូវបានគេបែងចែកជា៧ ប្រភេទធំៗ៖

- ឥណទានអចលនទ្រព្យ (Real Estate Loans): ប្រភេទឥណទាននេះតម្រូវអោយអ្នកខ្ចីមូលនិធិត្រូវមាន អចលនទ្រព្យដូចជា ដី និងអា- គារជាដើម ដើម្បីធានាលើឥណទាន។ ឥណទានអចលនទ្រព្យនេះរួមមាន ឥណទានរយៈពេលខ្លី សម្រាប់ការយកទៅសាងសង់និងអភិវឌ្ឍន៍ដី និងឥណទានរយៈពេលវែងសម្រាប់ការទិញដីផ្ទះអាគារស្នាក់នៅនិងអាគារពាណិជ្ជកម្មជាដើម។
- ឥណទានស្ថាប័នហិរញ្ញវត្ថុ (Financial Institution Loans): ជាឥណទានដែលផ្តល់ទៅអោយធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនហិរញ្ញវត្ថុ និង ស្ថាប័នហិរញ្ញវត្ថុនានា។
- ឥណទានកសិកម្ម (Agricultural Loans): ជាឥណទានដែលផ្តល់ទៅអោយកសិករ និងម្ចាស់កសិដ្ឋាន ដើម្បីជាជំនួយដល់ការដាំដុះ ការប្រមូលផល និងទ្រទង់ដល់ការចិញ្ចឹម និងថែរក្សាសត្វ។
- ឥណទានពាណិជ្ជកម្ម និងឧស្សាហកម្ម (Commercial and Industrial Loans): ជាឥណទានដែលផ្តល់ទៅអោយអាជីវករ និងអ្នកវិនិយោគសម្រាប់ការទិញសន្ទធិ ការបង់ ពន្ធផ្សេងៗ

[12] តាំង សុវណ្ណមុនីធំ និង ផុន សាយ័ន, ២០១៥, "ការផ្តល់ឥណទានសម្រាប់អាជីវកម្ម" ទំព័រទី១០

[13] រីទ្ធ ដុលារី និង តាំង រ៉ាឌី, ២០១២, «ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ », ទំព័រទី៨

និងការចំណាយលើប្រាក់ខែ បុគ្គលិកជាដើម។

- ឥណទានសម្រាប់អ្នកប្រើប្រាស់ (Individual Loans): ជាឥណទានដែលផ្តល់សម្រាប់ការទិញយានយន្ត គ្រឿងសម្ភារៈបរិក្ខារ គ្រឿងសង្ហារឹម គ្រឿងអេឡិចត្រូនិច និងទំនិញលក់រាយផ្សេងៗ ដើម្បីយកទៅជួសជុល និងលម្អរសោភណ្ឌភាព គេហដ្ឋាន។ ជាមួយគ្នានេះ ឥណទាននេះគឺផ្តល់ សម្រាប់ការចំណាយលើការព្យាបាល និងការ ថែរក្សាសុខភាព និងការចំណាយបុគ្គលផ្សេងៗទៀត។ ឥណទាននេះត្រូវបានផ្តល់ឲ្យដោយផ្ទាល់ ទៅកាន់អ្នកប្រើប្រាស់ ឬដោយប្រយោលតាមរយៈអ្នកលក់រាយ។

- ឥណទានសម្រាប់ជួល (Lease Financing Receivables): ជាឥណទានដែលម្ចាស់បំណុល ទិញនូវសម្ភារៈ ឬយានយន្ត រួចជួលទៅឲ្យអតិថិជនរបស់ពួកគេ។

- ឥណទានផ្សេងៗ (Miscellaneous Loans) : ជាឥណទានដែលមិនរាប់បញ្ចូលនូវប្រភេទឥណទានដែលបានរៀបរាប់ខាងលើ។ តួយ៉ាង ឥណទានមូលបត្រគឺជាបានរាប់បញ្ចូលក្នុងប្រភេទឥណទាននេះ។[14]

## ១.៥ លក្ខខណ្ឌក្នុងការផ្តល់ឥណទាន

### ១.៥.១ ការត្រួតពិនិត្យលើ៥Rs[15]

- Right Person (ការផ្តល់ចំមនុស្សត្រឹមត្រូវ)
  - ➢ ចរិកលក្ខណ: (Character)
    - អត្តចរិកល្អ, សុចរឹត, ទៀងត្រង់
    - មានអំណត់អត់ធន់ ព្យាយាម ឧស្សាហ៍
    - ប្រវត្តរស់នៅក្នុងសង្គម (Social Record)
  - ➢ មានកេរ្តិ៍ឈ្មោះល្អ
    - មានទំនាក់ទំនងល្អ

១៤ Peter S.R & Sylvia C.H; (2013), Book Management & Financial Service, 9th edition, Published by McGraw Hill, NY, Page 522

15 https://www.google.com/search?q=anlysis+loan+customer&ie=utf-8&oe=utf-8&aq=t&rls=org.mozilla:en-US:official&client=firefox-a&channel=sb

- មានវប្បធម៌ល្អក្នុងការរស់នៅ
- មានជំនាញ បទពិសោធន៍លើមុខរបរ

➢ ការទទួលខុសត្រូវ (Responsibility)

- មានសេចក្ដីអង់អាចក្នុងការងារ
- ការប្ដេជ្ញាចិត្តខ្ពស់ក្នុងការសងបំណុល ការធានា

➢ សុខភាព (Health)

- សុខភាពរឹងមាំគ្មានជំងឺរ៉ាំរ៉ៃ

• Right Business (ការផ្ដល់ឥណទានចំមុខរបរដែលមានសក្ដានុពល)

ភ្នាក់ងារឥណទានត្រូវស្វែងយល់ និងវិភាគទៅលើមុខរបររបស់អតិថជនដូចខាងក្រោម៖

➢ ប្រភេទនៃមុខរបរ ប្រវត្តនៃមុខរបរ

➢ ពិនិត្យមើលប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង

➢ ពិនិត្យមើលអ្នកជំនាញ

➢ ពិនិត្យលើប្រព័ន្ធដំណើរការ និងស្ថានភាពហិរញ្ញវត្ថុ

• Right Amount (សមត្ថភាពសង)

សមត្ថភាពសងអាចកើនឡើងស្របទៅ និងការជឿជាក់របស់ភ្នាក់ងារឥណទានមានកំរិតណាក្រោយពីបានធ្វើការប្រមូលព័ត៌មាន និងបានធ្វើការវាយតំលៃពីការផ្ដល់ប្រាក់កម្ចីរួច។ បច្ចុប្បន្ននេះធនាគារនិង ស្ថាប័នមីក្រូហិរញ្ញវត្ថុភាគច្រើនតាង X តំណាងឲ្យភាពជឿជាក់។ តំលៃ X មានការប្រែប្រួលអាស្រ័យលើភ្នាក់ងារឥណទានជាអ្នកកំណត់បើ៖

➢ បើភ្នាក់ងារឥណទានមានភាពជឿជាក់ខ្លាំងត្រូវឲ្យ X = 1,5

➢ បើភ្នាក់ងារឥណទានមានភាពជឿជាក់មធ្យមត្រូវឲ្យ X = 2

➢ បើភ្នាក់ងារឥណទានមានភាពជឿជាក់តិចតួចចំពោះរបរទើបតែចាប់ផ្ដើមត្រូវឲ្យ X = 3

• Right Time (ការផ្ដល់កម្ចីត្រូវពេលវេលា)

ក្នុងការផ្ដល់ឥណទាន ត្រូវបានធ្វើឡើងទៅតាមរដូវកាលនៃការចាប់ផ្ដើមផ្ដល់ឥណទាន និងត្រូវកំណត់កាលបរិច្ឆេទឲ្យមានច្បាស់ និងអនុវត្តទៅតាមការកំណត់ក្នុងការប្រមូលទុន

ត្រឡប់មកវិញ។ ផ្តល់ទុន និងកំណត់រយៈពេលត្រូវឲ្យសមស្របទៅតាមរយៈពេលនៃការប្រកបមុខរបរ ផ្តល់ទុនត្រូវពេលតាមតម្រូវការនៃមុខរបរ។[16]

**១.៥.២ ការវិភាគលើ៦C**

នៅពេលដែលផ្តល់ឥណទានទៅកាន់អតិថិជន មន្ត្រីឥណទានត្រូវធ្វើការពិនិត្យ ឬវិភាគទៅលើចំនុចទាំង៦ដែលគេហៅថា 6C's អោយបានច្បាស់លាស់ជាមុនសិន។ ចំនុចទាំងនោះមានដូចជា៖

- ចរិកលក្ខណៈ (Character): សំដៅទៅលើចរិតលក្ខណៈរបស់អតិថិជន ដែលក្នុងនោះរួមមាន គោលបំនងនៃការស្នើសុំឥណទាន ការទទួលខុសត្រូវលើកម្ចី ភាពស្មោះត្រង់ និងការខិតខំប្រឹងប្រែង របស់អតិថិជនក្នុងការសងត្រលប់នៃកម្ចីវិញ។

- លទ្ធភាព (Capacity): ពិនិត្យលើលទ្ធភាពផ្លូវច្បាប់របស់អតិថិជន ថាតើគាត់ជាអនីតិជន ឬនីតិជន និកម្មជន ឬអនិកម្មជន ហើយគាត់អាចស្នើសុំកម្ចីស្របច្បាប់ដែលឬទេ និងមានសិទ្ធិចុះហត្ថ- លេខាលើកិច្ចព្រមព្រៀងដែរឬអត់?

- សាច់ប្រាក់ (Cash): ត្រូវមើលលើលំហូរសាច់ប្រាក់របស់អតិថិជន ដើម្បីអោយប្រាកដថាគាត់ អាចនឹងមានលទ្ធភាពសងមកវិញទាន់ពេលវេលាឬទេ។ ហើយប្រភពចំនូលអាចមាន ២ គឺលំហូរសាច់- ប្រាក់ពីការលក់ ឬប្រាក់ចំនូល និងហិរញ្ញប្បទានដោយការបោះមូលបត្រ។

- វត្ថុបញ្ចាំ (Collateral): ជាទ្រព្យទាំងឡាយណាដែលធានាក្នុងការសងនៃបំនុល នៅពេលដែល អតិថិជនមិនមានលទ្ធភាពសង។ វត្ថុបញ្ចាំអាចជា គណនីឥណទេយ្យ សន្និធិ មូលបត្រទ្រព្យសកម្ម និងការធានាពីតតិយជន។

- ស្ថានភាព (Condition): សំដៅទៅលើស្ថានភាពការងារ ឬមុខជំនួញរបស់អតិថិជន និងលក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន ឬវិស័យផ្សេងទៀតដែលពាក់ព័ន្ធ ដើម្បីអោយដឹងថាមុខរបររបស់អតិថិជនមានដំណើរការល្អឬទេ? បើសិនវាមិនមានដំនើរការល្អនោះទេវានឹងធ្វើអោយប៉ះពាល់ដល់ចំនូលរបស់ គាត់ នោះការសងក៏ត្រូវរងនូវផលប៉ះពាល់ផលដែរ។

- ការគ្រប់គ្រង (Control): ចំនុចចុងក្រោយនេះពិនិត្យលើច្បាប់ និងបទបញ្ញា។ បើសិនជាច្បាប់ មានការកែប្រែនាពេលអនាគត តើមានការជះឥទ្ធិពលអ្វីខ្លះទៅលើកម្ចី? បញ្ហាទាំងអស់នោះ

[16] រឹទ្ធ ដុលារី និង តាំង វ៉ាឌី, ២០១២, «ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ», ទំព័រ ១៨

អាស្រ័យ ទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាល បើសិនជាការប្រែប្រួលមានភាពវិជ្ជមាន នោះនាំអោយ កម្ចីនឹងប្រឈមនឹងបញ្ហាអាក្រក់។[17]

### ១.៥.៣ ដំណើរការនៃការផ្តល់ឥណទាន

<u>ជំហានទី១</u> ទទួលពាក្យស្នើសុំខ្ចី ពីអតិថជន នៅពេលដែលអតិថជន មកសុំខ្ចីឥណទានស្ថាប័នហិរញ្ញវត្ថុទាមទារឲ្យអតិថជនបំពេញនូវរាល់ព័ត៌មានទាំងឡាយដែលមាននៅមាននៅក្នុងពាក្យស្នើសុំ។ ជាទូទៅក្នុងដំណាក់នេះមន្ត្រីឥណទានត្រូវពិនិត្យមើលថា តើគោលបំណងខ្ចីឥណទានរបស់អតិថជនសមស្របទៅនិងការទាមទាររបស់ច្បាប់ និងគោលការណ៍របស់ធនាគារដែរឬទេប្រសិនបើវាមានត្រូវតាមលក្ខខណ្ឌទាមទារ ធនាគារនិងមិនផ្តល់ឥណទានតាមសំណើរឡើយ។

<u>ជំហានទី២</u> ទាមទារឯកសារពាក់ព័ន្ធ ឬរបាយការណ៍ហិរញ្ញវត្ថុ។ ចំពោះឯកសារដែលពាក់ព័ន្ធសម្រាប់អតិថជនខ្ចីឥណទានប្រើប្រាស់ផ្ទាល់ខ្លួនមានដូចជាប័ណ្ណបើកបរ របាយការណ៍ចំណូលឬប្រាក់ខែ ភស្តុងតាងនៃចំណូលចេញពីប្រភពផ្សេងៗ របាយការណ៍លំអិតប្រចាំខែ និងរបាយការណ៍លំអិតទៅលើទ្រព្យដែលត្រូវបានប្រើប្រាស់ឥណទានដើម្បីទិញ។ សម្រាប់ឥណទានពាណិជ្ជកម្មអ្នកខ្ចីត្រូវមានត្រូវមានឯកសារដូចជា ឯកសារកម្មសិទ្ធិអាជីវកម្ម របាយការណ៍ហិរញ្ញវត្ថុដូចជា Balance Sheet, Income Statement និងចំណាយសាច់ប្រាក់ដែលមានរយៈពេល៣ទៅ៥ឆ្នាំ។

<u>ជំហានទី៣</u> ធ្វើការពិនិត្យលើពាក្យស្នើរសុំ និងឯកសារពាក់ព័ន្ធ។ ប្រសិនបើព័ត៌មានរបស់អតិថជននៅមានចន្លោះ ឬក៏មិនទាន់គ្រប់គ្រាន់ មន្ត្រីឥណទានត្រូវឲ្យអតិថជនបំពេញបន្ថែមនិងនាំយកឯកសារដែលខ្វះខាត់។ នៅក្នុងជំហាននេះការសម្រេចចិត្តផ្តល់ ឬមិនផ្តល់ឥណទានមិនទាន់បានធ្វើនៅឡើយទេ គឺរង់ចាំនៅជំហានបន្ទាប់។

<u>ជំហានទី៤</u> ប្រសិនបើព័ត៌មានទាំងអស់ត្រូវបានទទួល ប្រធានមន្ត្រីឥណទាន អាចកំណត់បានថាត្រូវឲ្យខ្ចីសម្រាប់ឥណទានផ្ទាល់ខ្លួន ដោយមិនទាន់កំណត់ពីទំហំជាក់លាក់នៅឡើយទេ

[17] ហ៊ួត ចរណៃ និង ម៉ក់ ទេវិន្ទ, ២០១៣, "ការផ្តល់ឥណទានសម្រាប់ពង្រីអាជីវកម្ម" ទំព័រទី១៥

ក្នុងជំហាននេះ។ សម្រាប់ឥណទានអាជីវកម្ម មន្ត្រីឥណទានត្រូវពិនិត្យមើលជំហ៊ានខាងក្នុងបន្ថែមទៀតដូចជាការចុះទៅដល់ទីតាំងអាជីវកម្មរបស់អ្នកខ្ចីផ្ទាល់ដើម្បីស្វែងរកព័ត៌មានបន្ថែម។

ជំហានទី៥ វាយតំលៃលំអិតទៅលើបច្ចេកទេស ពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងការគ្រប់គ្រងរបស់ក្រុមហ៊ុនសម្រាប់ឥណទានអាជីវកម្ម។

ជំហានទី៦ កំណត់នូវតម្រូវការហិរញ្ញវត្ថុរបស់អ្នកខ្ចី ទាំងឥណទានផ្ទាល់ខ្លួន និងពាណិជ្ជកម្ម។ ក្នុងករណីនេះមន្ត្រីឥណទានត្រូវកំណត់ទឹកប្រាក់ដែលផ្តល់កំចីដល់អតិថជនបាន។

ជំហានទី៧ នៅពេលដែលទំហំឥណទានត្រូវបានកំណត់រួចរាល់ហើយ ធនាគារត្រូវជូនដំណឹងទៅអតិថជន និងអញ្ជើញគាត់មកចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនៅធនាគារផ្ទាល់។ ក្នុងករណីដែលធនាគារមិនអាចផ្តល់ឥណទានឲ្យគាត់បាន ធនាគារត្រូវជូនដំណឹងដោយផ្ទាល់ដោយភ្ជាប់ជាមួយនិងហេតុផលយ៉ាងសមស្របដល់អតិថជន។

ជំហានទី៨ ក្នុងជំហាននេះធនាគារនិងផ្តល់ឥណទានដល់អតិថជន ក្នុងគោលបំណងដើម្បីឲ្យឥណទានប្រើប្រាស់ចំទិសដៅ ជាទូទៅធនាគារនិងធ្វើការទូទាត់ឲ្យអ្នកផ្គត់ផ្គង់របស់អតិថជនដោយផ្ទាល់តែម្តងសម្រាប់ការទិញទំនិញ។

ជំហានទី៩ ត្រួតពិនិត្យនិងតាមដានលើគណនីរបស់អតិថជនជាប្រចាំ។ នៅក្នុងស្ថានភាពខ្លះធនាគារទាមទារឲ្យអតិថជនបញ្ជូននូវរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំ ដើម្បីដឹងពីស្ថានភាពរបស់អ្នកខ្ចី ឬក្រុមហ៊ុន។

ជំហានទី១០ ប្រុងប្រយ័ត្ននិងចាត់វិធានការជាបន្ទាន់នៅពេលគណនីរបស់អតិថជនមានបញ្ហា។ ក្នុងករណីអតិថជនធ្វើការទូទាត់មិនទាន់ពេល ឬមិនធ្វើការទូទាត់ វានាំឲ្យសមតុល្យទធគណនីជំពាក់របស់អតិថជន មិនមានការថយចុះដែលនាំទៅរកឥណទានដែលមានបញ្ហា។ ដូច្នេះធនាគារត្រូវធ្វើការដោះស្រាយភ្លាមៗកុំឲ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ។[18]

### ១.៥.៤ ការត្រួតពិនិត្យឥណទានឡើងវិញ

នៅពេលដែលកម្ចីមួយបានកើតឡើង ក្នុងគោលបំនងសំខាន់នៃការត្រួតពិនិត្យនេះត្រូវបែងចែកជាពីរ គឺត្រួតពិនិត្យនូវសកម្មភាពកម្ចីដែលមានស្រាប់និងការដោះស្រាយកម្ចីដែលមានបញ្ហា។

[18] រឹទ្ធ ដុលារី និង តាំង វ៉ាឌី, ២០១២, «ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ», ទំព័រ១៧

សព្វថ្ងៃនេះ ធនាគារបានធ្វើការត្រួតពិនិត្យឥណទាន របស់ខ្លួនដោយ ប្រើប្រាស់នីតិវិធីផ្សេងៗ។ មូលដ្ឋានទូទៅមួយចំនួនត្រូវបានប្រើប្រាស់ដោយធនាគារភាគច្រើនរួមមាន៖

- ការអនុវត្ត ការត្រួតពិនិត្យឡើងវិញនូវរាល់ឥណទានគ្រប់ប្រភេទទៅតាមរយៈពេល។ ឥណទានធំៗត្រូវបានត្រួតពិនិត្យជាប្រចាំ និងជ្រើសរើសដោយចៃដន្យចំពោះឥណទានតូចៗ។
- បង្កើតនូវនីតិវិធីតាមដានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ដើម្បីបញ្ជាក់ថាលក្ខណៈសំខាន់របស់ឥណទានត្រូវបានគេធ្វើការត្រួតពិនិត្យដែលរួមមាន៖

- កំនត់ត្រាអំពីការសងរបស់អ្នកខ្ចី ដើម្បីបញ្ជាក់ពីការសងទៀងទាត់តាមកាលវិភាគសងប្រាក់ដែលបានកំនត់ ។
- គុណភាព និងស្ថានភាពនៃហិរញ្ញវត្ថុបញ្ចាំ ។
- ធ្វើការវាយតម្លៃពីស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី និងព្យាករណ៍ការផ្លាស់ប្តូរនូវអ្វីដែលអាចធ្វើអោយមានការថយចុះ ឬមានការកើនឡើងនូវតម្រូវការឥណទានរបស់អតិថិជន។
- ត្រួតពិនិត្យឡើងវិញអោយបានទៀងទាត់ចំពោះឥណទានធំៗ ពីព្រោះវាអាចបង្កជាហានិភ័យចំពោះស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ។
- ត្រួតពិនិត្យឥណទានដែលមានបញ្ហា អោយបានញឹកញាប់ជាងគេការត្រួតពិនត្យឥណ- ទានមានសារៈសំខាន់ណាស់ សម្រាប់កម្មវិធីផ្តល់ឥណទានរបស់ធនាគារដ៏ល្អមួយ។ វាមិនត្រឹមតែ អោយអ្នកគ្រប់គ្រងរកឃើញឥណទានមានបញ្ហាបានឆាប់រហ័សប៉ុណ្ណោះទេ ថែមទាំងអាចពិនិត្យពីភ្នាក់ងារឥណទានក្នុងការប្រកាន់ខ្ជាប់នូវគោលនយោបាយឥណទានរបស់ធនាគារ។ [19]

## ១.៦ ការគណនាអត្រាការប្រាក់

ក្នុងការគណនាអត្រាការប្រាក់ វាជារឿងមួយដ៏សំខាន់សម្រាប់គ្រប់ធនាគារទាំងអស់ត្រូវធ្វើការកំនត់។ ហើយការគណនាអត្រាការប្រាក់ គឺមិនមានលក្ខណៈដូចគ្នានោះទេ វាអាស្រ័យទៅលើគោលនយោបាយរបស់ធនាគារនីមួយៗ។ ជាទូទៅការប្រាក់ត្រូវបានបែងចែកជាពីរប្រភេទសំខាន់ៗ៖

[19] ហ្វូត ចរណៃ និង ម៉ក់ ទេវិន្ទ, ២០១៣, "ការផ្តល់ឥណទានសម្រាប់ពង្រីកអាជីវកម្ម" ទំព័រទី១៨

### ១.៦.១ ការប្រាក់ទោល ឬការប្រាក់សាមញ្ញ

#### ក.និយមន័យ

ការប្រាក់ទោល ឬការប្រាក់សាមញ្ញ គឺជាការប្រាក់ដែលគិតលើប្រាក់ដើម (ដែលបានខ្ចី) ក្នុងគ្រប់រយៈពេល។ ការប្រាក់របស់រយៈពេលនីមួយៗ មិនបានបូកបញ្ចូលជាមួយប្រាក់ដើម ដើម្បីយក ការប្រាក់នៅគ្រាក្រោយឡើយ។[20]

#### ខ.រូបមន្តគ្រឹះ

| | |
|---|---|
| ➢ រូបមន្តការប្រាក់សាមញ្ញ : | **I = Prt** |
| ➢ រូបមន្តប្រាក់សរុប: | **S = P(1+rt)** |

ដែល P ជាប្រាក់ដើម ឬប្រាក់បច្ចុប្បន្ន

I ជាការប្រាក់ t ជារយៈពេល

S ជាប្រាក់សរុប ឬប្រាក់អនាគត r ជាអត្រាការប្រាក់

ឧទាហរណ៍៖ បុរសម្នាក់ខ្ចីប្រាក់ពីធនាគារចំនួន 500 $ ជាមួយអត្រាការប្រាក់ប្រចាំឆ្នាំ 8,5 %។ តើបុរសនោះត្រូវបង់ប្រាក់ និងប្រាក់សរុបចំនួនប៉ុន្មាន? បើគាត់ខ្ចីប្រាក់នោះក្នុងរយៈពេល២ឆ្នាំ?

**<u>ដំណោះស្រាយ</u>**

ការប្រាក់ និងប្រាក់សរុបដែលបុរសនោះត្រូវបង់អោយធនាគារ

យើងមាន៖ ប្រាក់ដើម P = 500$ , អត្រាការប្រាក់ប្រចាំឆ្នាំ r = 8,5% និងរយៈពេល t = 2ឆ្នាំ

- ការប្រាក់សាមញ្ញ I = Prt = 500*0.85*2 = 85$
- S = P(1+rt) = 500(1+(0.085*2)) = 585$

### ១.៦.២ ការប្រាក់ផ្គួប ឬការប្រាក់សមាស

#### ក.និយមន័យ

ការប្រាក់សមាស ជាការប្រាក់ដែលគេធ្វើឡើងនៅចុងកំឡុងពេលនីមួយៗ ហើយការប្រាក់ដែលទទួលបាននៅចុងកំលុងពេលទី១ ត្រូវបូកបន្ថែមនឹងប្រាក់ដើម ដើម្បីធ្វើជាប្រាក់ដើមនៅកំឡុង ពេលទី២ សម្រាប់គិតការប្រាក់។ គេធ្វើរបៀបនេះរហូតដល់កំឡុងពេលចុងក្រោយ។

[20] ជា សែម និងឡាយ សុខឃាង, ២០១៣, «គណិតវិទ្យាសេដ្ឋកិច្ច», ទំព័រ ៣២

### ខ. រូបមន្តគ្រឹះ

- រូបមន្តប្រាក់សរុប: $S = P(1+r)^n$

ឧទាហរណ៍៖ បុរសម្នាក់ផ្ញើប្រាក់ 1000$ ជាមួយអត្រាការប្រាក់ប្រចាំឆ្នាំ r = 12% ។ គណនាប្រាក់សរុប ក្នុងរយៈពេល ៥ឆ្នាំ។

<u>**ដំណោះស្រាយ**</u>

យើងមានប្រាក់ដើម P = 1000$ អត្រាការប្រាក់ប្រចាំឆ្នាំ 12% និងកំលុងពេល n = 5ឆ្នាំ

តាមរូបមន្តប្រាក់សរុបយើងបាន $S = P(1+r)^n$

S = 1000(1*0.12)5 = 1762.34$

## ១.៧. របៀបសងប្រាក់

### ១.៧.១ ការសងតែការប្រាក់

ការសងតែការប្រាក់ គឺតម្រូវឲ្យអតិថជនបង់តែការប្រាក់ប្រចាំខែនីមួយៗរហូតដល់ខែចុងក្រោយទើបតម្រូវឲ្យអតិថជនបង់ទាំងការប្រាក់ និងប្រាក់ដើម។

តាមរូបមន្ត

ការប្រាក់= ប្រាក់ដើមនូវជំពាក់ x អត្រាការប្រាក់

សំណងប្រចាំគ្រា= ការប្រាក់ + រំលោះប្រាក់ដើម

### ១.៧.២ សំណងដោយរំលោះតាមលំដាប់ចុះ

សំណងដោយរំលោះតាមលំដាប់ចុះ តម្រូវឲ្យអតិថជនសងត្រលប់មកវិញដោយរំលោះនូវប្រាក់ដើមក្នុងចំនួនមួយថេរ រហូតទាល់តែសមតុល្យស្មើសូន្យនៅគ្រាចុងក្រោយ។ វិធីសាស្ត្រនេះអត្រាការប្រាក់ និងប្រាក់ និងប្រាក់ដើមមានការថយចុះជាបន្តបន្ទាប់។

តាមរូបមន្ត

A= PV/t

A ជាប្រាក់ដើមថេរដែលត្រូវបង់ប្រចាំខែ

PV ប្រាក់ដើមសរុបដែលបានខ្ចី

t រយៈពេលខ្ចី

ការប្រាក់ = ប្រាក់ដើមនូវជំពាក់ x អត្រាការប្រាក់ (I=PV x r)

P ប្រាក់ដើមនូវជំពាក់ , r អត្រាការប្រាក់

សំណងប្រចាំគ្រា = ជាប្រាក់ដើមថេរដែលត្រូវបង់ប្រចាំខែ + ការប្រាក់(C=A+I)[21]

[21] រិទ្ធ ដុល្លារី និង តាំង ប៉ាឌី, ២០១២ "ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ" ទំព័រ១៣

### ១.៧.៣ វិធីសាស្ត្រសំណងប្រចាំគ្រាថេរ

សំណងប្រចាំគ្រាថេរ គឺជាសំណងដែលតម្រូវឲ្យអតិថជន បង់រំលោះនូវចំនួនថេរណាមួយជារៀងរាល់ខែរហូរដល់សមតុល្យស្មើសូន្យ។[22]

## ១.៨ ហានិភ័យឥណទាន

### ១.៨.១ និយមន័យហានិភ័យឥណទាន

ហានិភ័យឥណទានគឺជាកំរិតនៃគ្រោះថ្នាក់ដែលកើតឡើងចំពោះប្រាក់កំចីរបស់ធនាគារ ដោយទទួលរងនូវការខាត់បង់ដោយសារតែអតិថជនខ្លួនមិនសងបំណុលតាមកិច្ចសន្យា ឬសង មិនគ្រប់ចំនួនទឹកប្រាក់ទាំងដើមទាំងការ។ ហានិភ័យប្រភេទនេះជាហានិភ័យដែលធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចក្ស័យធនបាន។[23]

### ១.៨.២ មូលហេតុដែលបណ្តាលឲ្យមានហានិភ័យ

នៅក្នុងដំណាក់កាលដំបូងនៃកម្ចីមានបញ្ហា ផ្អែកតាមសញ្ញាព្រមានដូចខាងក្រោម៖

- ការពន្យារពេលទទួលព័ត៌មានហិរញ្ញវត្ថុ ជាពិសេសប្រសិនបើកិច្ចសន្យានៃកូនបំណុលតម្រូវ អោយបញ្ជូនឯកសារទាំងនោះអោយបានទាន់ពេលវេលា
- ក្រុមហ៊ុនផ្លាស់ប្តូរអ្នកគ្រប់គ្រង ឬអ្នកត្រួតពិនិត្យ
- ការផ្លាស់ប្តូរយ៉ាងលឿន នៅក្នុងដែនការពារពាណិជ្ជកម្មមូលដ្ឋានរបស់អតិថិជន និងការ ផ្លាស់ប្តូរដែលបានសង្ឃឹមទុក នៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន និងនិន្នាការមិនល្អនៃទីផ្សាររបស់ អតិថិជន (ការលក់ធ្លាក់ចុះនាំអោយប្រាក់ចំនេញថយចុះ)។[24]

## ១.៩ ការគ្រប់គ្រងហានិភ័យឥណទាន

### ១.៩.១ ការត្រួតពិនិត្យបំណុល

ការស្វែងយល់អំពីអត្តសញ្ញាណទាន់ពេលវេលានៃបញ្ហាលំបាករបស់កូនបំនុល ធ្វើអោយធនាគារ មានការប៉ាន់ស្មានប្រមាណនៃសភាពជាក់ស្តែង និងបង្កើតយុទ្ធសាស្ត្រទប់ទល់នឹងបញ្ហាទាន់ពេល វេលា។ នៅពេលមន្ត្រីឥណទានដឹងថាកម្ចីដែលបានផ្តល់ទៅកាន់អតិថិជនកាន់តែ

[22] PER ZIMA and L.BROWN.Mathematics of Finance(pg 125)

[23] រិទ្ធ ដុល្លារី និង តាំង ព៉ឌី, ២០១២ "ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ" ទំព័រ២៤

[24] ហួត ចរណៃ និង ម៉ក់ ទេវិទ្ធ, ២០១៣, "ការផ្តល់ឥណទានសម្រាប់ពង្រីកអាជីវកម្ម" ទំព័រទី១៩

មានភាពធ្ងន់ធ្ងរ ហើយនោះ វាគឺជាពេលដែលគួរតែពិនិត្យ និងចាត់វិធានការដោះស្រាយដូចខាងក្រោម៖

- វិភាគបញ្ហារបស់កូនបំណុល
- សំនូមពរពន្យារពេលទូទាត់ការប្រាក់សិនបើចាំបាច់
- ប្រមូលព័ត៌មានសរុបពីគ្រឹះស្ថានហិរញ្ញវត្ថុដែលពាក់ព័ន្ធជាមួយកូនបំណុល
- ត្រួតពិនិត្យសកម្មភាពគណនីសម្រាប់ឥណទានវិបារូប ឬវត្ថុបញ្ចាំ

### ១.៩.២ បំណុលមានបញ្ហា និងដំណោះស្រាយ

រាល់បំនុលដែលមានបញ្ហា គឺសុទ្ធតែមានលក្ខណៈខុសៗគ្នា និងមិនមែនមានវិធីតែមួយទេក្នុងការ ដោះស្រាយ។ មានវិធីសាស្ត្រសំខាន់មួយចំនួនដូចខាងក្រោម៖

- បង្កើតកម្មវិធីរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ
- ពិនិត្យឡើងវិញនូវការរៀបចំឯកសារ និងការធានា ៖

ក្នុងករណីដែលឥណទានមានបញ្ហាគឺមន្ត្រីឥណទានចាំបាច់ត្រូវត្រួតពិនិត្យឡើងវិញនូវឯកសារដែលពាក់ព័ន្ធនឹងឥណទានរបស់អតិថិជន ដើម្បីស្វែងរកចំណុចខ្វះខាតដែលកើតមានឡើងដោយ អចេតនាដូចជា ការរាយការណ៍មិនបានត្រឹមត្រូវពីប្រវត្តិរូបរបស់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់ អតិថិជនជាដើម។

- រក្សាទុកវត្ថុបញ្ចាំបន្ថែម ៖ ប្រសិនបើធនាគារប៉ាន់ប្រមាណបានពីហានិភ័យនៃឥណទានដែលនឹងកើតឡើង ធនាគារអាចស្នើសុំទៅអតិថិជនដើម្បីបន្ថែមនូវវត្ថុ ឬទ្រព្យដាក់ធានា ឬបញ្ចាំ បន្ថែម ដើម្បីធានានូវស្ថិរភាពនៃឥណទាន
- ស្វែងរកមូលនិធិបន្ថែម ៖ ក្នុងករណីដែលឥណទានមានបញ្ហាធ្ងន់ធ្ងររហូតដល់អតិថិជនបាត់បង់សមត្ថភាពសង នោះឥណទាននឹងត្រូវបានចាត់ជាបំណុលអាក្រក់ ហើយធនាគារក៏នឹងមិន អាចទទួលបានប្រាក់ត្រលប់មកវិញ។ នេះជាហេតុដែលធនាគារចាំបាច់ត្រូវស្វែងរកមូលនិធិបន្ថែម ពោលគឺ មូលធនបន្ថែម ដើម្បីបង្គ្រប់នូវសមតុល្យដែលបាត់បង់។
- លក់វត្ថុបញ្ចាំ ៖ រាល់ឥណទានគឺធនាគារតម្រូវអោយអតិថិជនដាក់ទ្រព្យសម្បត្តិធានាទៅលើបំណុល ដើម្បីកាត់បន្ថយហានិភ័យដែលនឹងអាចកើតមានឡើងចំពោះឥណទាន។ ក្នុង

ករណី ដែលឥណទានមានបញ្ហា ធនាគារមានសិទ្ធិស្នើសុំទៅកាន់អតិថិជនអោយលក់ទ្រព្យដាក់ធានារបស់ ខ្លួនដើម្បីយកប្រាក់មកទូទាត់សងបំណុលរបស់ធនាគារ។

- ចាត់វិធានការច្បាប់ ដូចជាកោះហៅអ្នកធានាមកសងបំណុល ៖ ក្រៅពីដាក់ទ្រព្យបញ្ចាំ ឬធានា ធនាគារក៏ទាមទារអោយមានតតិយជនធ្វើការធានាចំពោះបំណុលរបស់អតិថិជនផងដែរ។ ប្រសិនបើឥណទានមានបញ្ហា ធនាគារមានសិទ្ធិបង្ខំអោយតតិយជនដែលជាអ្នកធានាបំណុលនោះ ចេញសងជំនួសអតិថិជនបានដោយយោងតាមកិច្ចព្រមព្រៀង។
- ជំនួសថ្នាក់ដឹកនាំថ្មី ៖ ធនាគារអាចមានសិទ្ធិស្នើសុំទៅកាន់អតិថិជន (នីតិបុគ្គល) អោយ ធ្វើការផ្លាស់ប្តូរអ្នកដឹកនាំដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ របស់រោងចក្រ សហគ្រាសនោះ ក្នុងគោលបំណងបន្តអោយមានភាពប្រសើរឡើងវិញនូវការសងត្រលប់មកធនាគារវិញនូវឥណទានដែលមានបញ្ហា។
- រៀបចំឯកសារសម្រាប់ការក្ស័យធន ៖ ការប្រកាសក្ស័យគឺចាំបាច់ត្រូវឆ្លងកាត់ការចេញសាលក្រមពីតុលាការ ។ ការណ៍នេះគឺដើម្បីអោយម្ចាស់បំណុលអាចមានសិទ្ធិអោយកូនបំណុលលក់ ឡៃឡុងនូវរាល់របស់ទ្រព្យដែលក្រុមហ៊ុនមាន យកមកសងដល់ម្ចាស់បំណុលវិញ។[25]

[25] Robert Cole & Lon Mishier, 1998, “Credit Management”, Page 408

# ជំពូកទី ២
# ស្ថានភាពទូទៅរបស់
# ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់

## ២.១ ប្រវត្តិរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់

ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៦ មានឈ្មោះពេញថា ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ដើម្បីផ្តល់សេវាធនាគារពាណិជកម្មដល់អតិថិជនជាសាជីវកម្មមួយចំនួនប៉ុណ្ណោះ។ ប៉ុន្តែបច្ចុប្បន្នធនាគារបានផ្តល់សេវាធនាគារពេញលេញតាមរយៈបណ្តាញប្រាស្រ័យទាក់ទងទំនើបៗទាំងអស់ដល់ប្រជាពលរដ្ឋគ្រប់រូប។

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ផ្តល់សេវាហិរញ្ញវត្ថុជាច្រើនដល់អតិថិជនជាបុគ្គល សហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងអង្គភាពសាជីវកម្មនានាផងដែរ។ គិតត្រឹមខែមិនា ឆ្នាំ ២០១៥នេះ យើងមានសាខាទាំងអស់ចំនួន ២៧ ទូទាំងប្រទេស ហើយក៏គ្រោងនឹងពង្រីកអោយបានរហូត ៥០ សាខានៅត្រឹមចុងឆ្នាំ ២០១៧ ខាងមុខនេះ។ កាលពីខែកក្កដា ឆ្នាំ២០១៤ កន្លងទៅនេះ ធនាគារជាតិនៃកាណាដា (www.nbc.ca) បានក្លាយជាម្ចាស់ក្រុមហ៊ុនដ៏សំខាន់របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់។

ទស្សនាវដ្តីហិរញ្ញវត្ថុដ៏ល្បីល្បាញបំផុតរបស់ពិភពលោក បានទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងរបស់យើងដែលបាននាំមកជូនអតិថិជននូវសេវាកម្មល្អប្រសើរបំផុត។ នៅក្នុងឆ្នាំ២០១៤ ទស្សនាវដ្តី The banker បានឧទ្ទេសនាមធនាគារ វឌ្ឍនៈអាស៊ីចំកាត់ ថាជា "ធនាគារឆ្នើមបំផុតក្នុងប្រទេសកម្ពុជាប្រចាំឆ្នាំ២០១៤" ។ ពានរង្វាន់នេះទទួលស្គាល់ភាពខ្លាំងផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រងដ៏រឹងមាំ វិធីសាស្ត្រដោះស្រាយហានិភ័យជាក់ស្តែង និងគំរូអាជីវកម្មដ៏រឹងមាំរបស់យើងផងដែរ។

ទស្សនាវដ្តី Euromoney ក៏បានឧទ្ទេសនាមធនាគារ វឌ្ឍនៈអាស៊ីចំកាត់ ថាជា "ធនាគារល្អប្រសើរបំផុតនៅក្នុងប្រទេសកម្ពុជា" ផងដែរ។ ចំពោះគុណភាព សេវាកម្ម ការច្នៃប្រឌិត និងកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការជំរុញសេវាកម្មនៅក្នុងវិស័យធនាគារនៅកម្ពុជាអោយឈានទៅមុខមួយកម្រិតទៀត។

ក្រោយពីបានផ្តល់សេវាកម្មធនាគារសំរាប់បុគ្គល និងសេវាកម្មប្រកបដោយភាពជោគជ័យនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមក នៅឆ្នាំ២០១១ ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ បានបង្វែរចំណាប់អារម្មណ៍ទៅកាន់វិស័យ "អាជីវកម្មខ្នាតតូច" ដោយមានគោលបំណងផ្តល់សេវាកម្មប្រសើរបំផុត ផែនការហិរញ្ញវត្ថុ និងលក្ខខណ្ឌធនាគារដល់សហគ្រាសខ្នាតតូច និងមធ្យ(SME)

ផលិតផលរបស់ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ រួមមាន (សេវាធនាគារតាមអ៊ីនធើណេត និងទូរស័ព្ទចល័ត) សេវាកាតទូទាត់ (រួមមាន MasterCard, Visa Card និង UnionPay Card) គណនីចល័ត គណនីសំចៃ គណនីមានកាលកំណត់ កម្ចីអាជីវកម្ម និងផ្ទាល់ខ្លួន ព្រមទាំងការដាក់ទ្រព្យធានាផងដែរ។

## ២.២ គោលបំណងនិង អត្ថប្រយោជន៍

### ២.២.១ គោលបំណង

គោលបំណងចំបងក្នុងការបង្កើនអោយមានប្រតិបត្តការឥណទានក៏ដូចជាសេវាទាំងអស់របស់ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ គឺក្នុងគោលបំណងៈ

- បន្ថែមទុនលើមុខរបរមានស្រាប់ (Additional working capital)
- ការទិញទ្រព្យផលិតកម្ម សម្រាប់អាជីវកម្មបច្ចុប្បន្ន (Acquisition of productive assets for current business)
- ការកែឆ្នៃផលិតផល(អាជីវកម្ម ឬផលិតផលកសិកម្ម) Production Process (business or agricultural production)
- ការពង្រីអាជីវកម្ម(Expansion of business)
- តម្រូវការសម្រាប់ចំណាយប្រតិបត្តិ (Operation needs)
- តម្រូវការសម្រាប់អាជីវកម្មផ្សេងៗ(Other business needs)
- តម្រូវការសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (Personal needs)[26]

❖ <u>ចំណាំ:</u>

- ភ្ញៀវត្រូវធានាថា ប្រាក់កម្ចីត្រូវបានប្រើប្រាស់សម្រាប់ គោលបំណងដែលបានរៀបរាប់នៅក្នុងពាក្យស្នើសុំប្រាក់កម្ចី។ ប្រសិនបើប្រាក់កម្ចីត្រូវបានប្រើប្រាស់ សម្រាប់គោលបំណងផ្សេងៗក្រៅពីអ្វីដែលបានរៀបរាប់ក្នុងពាក្យស្នើសុំប្រាក់កម្ចីដោយគ្មានមូលហេតុសមរម្យណាមួយទេនោះ ធនាគារ អាចនឹង ឲ្យភ្ញៀវសងត្រលប់ប្រាក់កម្ចីទាំងស្រុងមកធនាគារវិញ។
- ការផ្តល់ប្រាក់កម្ចីសម្រាប់អាជីវកម្មថ្មីដែលទើបនឹងចាប់ផ្តើមមិនត្រូវបានអនុញ្ញាតឡើយប្រសិនបើគ្មានអាជីវកម្មផ្សេងទៀត សម្រាប់ធ្វើការទូទាត់សងប្រាក់កម្ចី។
- ប្រសិនបើភ្ញៀវត្រូវការប្រាក់កម្ចីសម្រាប់ទិញរថយន្តឬផ្ទះ ហើយមានចំណូលពីប្រាក់ខែ ដូច្នេះយើងគួរផ្តល់ប្រាក់កម្ចីជា កម្ចីទិញឡានឬទិញផ្ទះ។

[26] តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋបាលឥណទាណប្រចាំសាខា ២០១៦

### ២.២.២ អត្ថប្រយោជន៍

- សម្រាប់ធនាគារ
  - ទទួលបានប្រាក់ចំណូលបន្ថែមតាមប្រតិបត្តិការឥណទាននិងប្រាក់បញ្ញើរអន្តរសាខា
  - អាចបំពេញតាមសេចក្តីត្រូវការ និង ការចង់បានរបស់អតិថជន។
  - ពង្រីក និងពង្រឹងឥទ្ធិពល និងកេរ្តិ៍ឈ្មោះរបស់ធនាគារ
  - ពង្រីកចំណែកទីផ្សារឲ្យកាន់តែទូលំទូលាយថែមទៀត
  - មានឱកាសលក់ផលិតផលផ្សេងៗទៀតក្នុងពេលតែមួយ
- សម្រាប់អតិថជន
  - មានសុវត្ថិភាពក្នុងការដក ដាក់ប្រាក់ ផ្ទេរ ឬទទួលប្រាក់
  - អាចពង្រីកអាជីវកម្មរបស់ខ្លួនឲ្យកាន់តែទូលំទូលាយ
  - មានឱកាសប្រើប្រាស់ និងសេវារបស់ធនាគារ
- សម្រាប់សង្គម
  - រួមចំណែកក្នុងការលើកស្ទួយ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមជាតិ
  - បង្កើតទីផ្សារការងារតាមរយៈប្រតិបត្តិការឥណទាន និងប្រាក់បញ្ញើរ
  - រួមចំណែកក្នុងការកាត់បន្ថយអសន្តិសុខសង្គមតាមរយៈការផ្តល់សេវាទាំងនេះ។

## ២.៣ ភាគទុនិករបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់

បច្ចុប្បន្ននេះ ធនាគារវឌ្ឍនៈអាស៊ីចំកាត់កំពុងតែដំណើរការវិនិយោគយ៉ាងរលូននៅក្នុងទីផ្សាររបស់ប្រទេសកម្ពុជាដោយស្ថិតនៅក្រោមការគ្រប់គ្រង និងតាមរយៈការចូលរួមភាគហ៊ុនរបស់ម្ចាស់ភាគទុនិកធំៗចំនួនពីរដូចជា៖

- លោក Damir Karassayav ជាអ្នកដឹកនាំមូលធនឯកជន និងវិជ្ជាជីវៈហិរញ្ញវត្ថុ ពោលគឺលោកបានយកចិត្តទុកដាក់ជាចំបងលើការអនុវត្តន៍ធនាគារ ABA ជាទ្រព្យសកម្មស្នូលរបស់លោកដែរកាន់កាប់ភាគហ៊ុនចំនួន ១០% នៃធនាគារទាំងមូល។
- ម្ចាស់ភាគទុនិកទីពីរគឺជាដៃគូរធនាគារជាតិនៃប្រទេសកាណាដា ( National Bank of Canada ) ជាស្ថាប័នហិរញ្ញវត្ថុកំរិត $A^+$ និង A ចំនាត់ថ្នាក់ដោយ Fitch and Standard & Poor's និងមានទ្រព្យសកម្មចំនួន២០០ពាន់លានដុល្លាកាណាដា ព្រមទាំងជាស្ថាប័នដែរមានដៃគូរបណ្តាញសហការដ៏ធំនៅទូទាំងពិភពលោកដែលកាន់កាប់ភាគហ៊ុនចំនួន ៩០% នៃធនាគារ។

## ២.៤ ផ្លាកសញ្ញា និងអត្ថន័យ

### ២.៤.១ ម៉ាកយីហោ

ម៉ាកយីហោរបស់ធនាគារ ABA ត្រូវបានអភិវឌ្ឍន៍ជាប់រហូតដើម្បីជួយរក្សារតំណែងរបស់ខ្លួន ក្នុងនាមជាអ្នកផ្តល់សេវាហិរញ្ញវត្ថុដ៏ទំនើបមួយដែលមានបច្ចេកវិទ្យាឈានមុខគេ មានស្ថិរភាពប្រកបដោយគុណភាពខ្ពស់ និងមានការអភិវឌ្ឍន៍ឥតឈប់ឈរ។

### ២.៤.២ ស្លាកសញ្ញា

ធាតុមូលដ្ឋាននៃម៉ាកយីហោរបស់យើងគឺផ្លាកសញ្ញា ហើយនេះគឺជាធាតុដ៏សំខាន់មួយក្នុងការបង្កើតអត្តសញ្ញាណសាជីវកម្មដ៏រឹងមាំ។ ស្លាក់សញ្ញានេះគឺជាអត្តសញ្ញាណកម្ម ជារូបភាពគន្លឹះដែលបង្កើតកេរ្តិ៍ឈ្មោះម៉ាកយីហោរួមមួយដែលនាំអោយមានការស្គាល់ធនាគារ វឌ្ឍនៈអាស៊ីចំកាត់នៅលើទីផ្សារ។ ជាមួយនឹងអត្តសញ្ញាណសាជីវកម្មនេះ យើងបង្ហាញថាតើយើងជានរណា និងតំណាងអោយអ្វីខ្លះ?

### ២.៤.៣ អត្ថន័យនៃស្លាកសញ្ញា

អត្ថន័យនៃស្លាកសញ្ញា៖ ពណ៌សុទ្ធ និងមានការរចនាចំៗដែលបង្ហាញអំពីសុវត្ថិភាព និងស្ថិរភាពដែលធនាគារ ABA ផ្តល់ជូនអតិថិជនរបស់ខ្លួន៖

- ការណែនាំ
- សន្តិភាពផ្លូវចិត្ត
- ឱកាសក្នុងការរីកចំរើន

➢ ធាតុពណ៌ក្រហម(ឆ្លុះ)៖ ធាតុពណ៌ក្រហមដែលមើលឃើញឆ្លុះលើផ្ទៃខាងក្រោយតំណាងអោយតម្លាភាព។

➢ ធាតុពណ៌ក្រហម៖ ធាតុពណ៌ក្រហមសង្កត់ធ្ងន់លើមនុស្សជាតិ និងថាមពលចេញពីក្នុងចិត្ត ប្រកបដោយភាពទាន់សម័យរបស់ខ្លួន ពោលគឺបំណងប្រាថ្នាចំពោះអ្វីដែលយើងធ្វើ។

➢ ពណ៌ខៀវខ្ចី៖ ពណ៌ខៀវខ្ចីតំណាងអោយឱកាសដូចមហាសមុទ្រ។

➢ ភាពសុទ្ធនៃពណ៌ខៀវចាស់៖ ភាពសុទ្ធនៃពណ៌ខៀវចាស់នៅផ្ទៃកខាងក្រោយរៀបរាប់សង្ខេបអំពីចំនុចសំខាន់ដែលមនុស្សគ្រប់គ្នារំពឹងចង់បានពីធនាគារ ABA ពោលគឺវត្តមានជាប្រចាំ និងប្រកបដោយទំនួលខុសត្រូវនៅក្នុងជីវិតរបស់មនុស្សគ្រប់រូប។

➢ តួអក្សរពណ៌ស៖ តួអក្សរពណ៌សតំណាងអោយភាពបរិសុទ្ធ នេះគឺជាការរចនាដ៏ស្អាតបរិសុទ្ធ និងទំនើបដែលមានភាពងាយស្រួលរួមជាមួយនឹងការធានាថាស្លាក់សញ្ញានេះនឹងនៅតែមាននភាពឆើតឆាយជារៀងដរាប។

**ទីតាំងភូមិសាស្ត្ររបស់ធនាគារវឌ្ឍៈ អាស៊ី ចំកាត់ សាខាស្ទឹងមានជ័យ**

ធនាគារវឌ្ឍៈ អាស៊ី ចំកាត់ សាខាស្ទឹងមានជ័យមានទីតាំងនៅផ្ទះលេខ ២០B និង២១B ផ្លូវលេខ២១៧ សង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ។



ទំនាក់ទំនងតាមរយៈ

លេខទូរស័ព្ទលេខ ៖ ០៩៨ ២៣០ ៨៨៩

អ៊ីម៉ែល ៖ stungmeanchey@ababank.com

វែបសាយ ៖ http://www.ababank.com

## ២.៥ ចក្ខុវិស័យ បេសកម្ម និងគុណតំលៃ

ចក្ខុវិស័យរបស់ធនាគារ គឺដើម្បីក្លាយជាធនាគារលំដាប់លេខមួយប្រចាំប្រទេសកម្ពុជាទៅលើផ្នែកនៃការផ្គត់ផ្គង់សេវាកម្មធនាគារគួជាទីទុកចិត្ត ងាយស្រួលក្នុងការប្រើប្រាស់ និងប្រកបដោយបច្ចេកវិទ្យាទំនើបបំផុត។ យើងមានបំណងក្លាយជាធនាគារមួយដែលប្រជាជនកម្ពុជាជឿទុកចិត្តក្នុងការថែរក្សាទ្រព្យផ្ទាល់ខ្លួន និងអាជីវកម្មទៅតាមតំរូវការរបស់អតិថិជន។

បេសកម្មរបស់ធនាគារ គឺដើម្បីជួយដល់ប្រទេសកម្ពុជា ពាណិជ្ជករ និងប្រជាជនកម្ពុជារួមគ្នាក្នុងការកសាងអនាគតឱ្យកាន់តែប្រសើរឡើង និងត្រចះត្រចង់សំរាប់ខ្លួនផ្ទាល់ និងប្រទេសកម្ពុជាតាមរយៈការផ្តល់សេវាកម្មធនាគារប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ និងបច្ចេកទេសទំនើបបំផុត។ ក្នុងនាមជាធនាគារក្នុងស្រុកមួយ យើងខ្ញុំចាត់ទុកខ្លួនជាដៃគូដ៏ល្អសំរាប់សហគមន៍កម្ពុជា ក៏ដូចជាអាជីវកម្ម និងបុគ្គលឯកជន។

- គុណតំលៃរបស់ធនាគារ៖
  - សុចរិត និងសេចក្តីគោរព៖ យើងចាត់ទុកចំនុចនេះជាការទទួលខុសត្រូវខ្ពស់របស់ធនាគារដែលត្រូវបំរើសេវាជូនដល់អតិថិជនដោយភាពសុចរិត និងសេចក្តីគោរព។
  - ទំនុកចិត្ត និងភាពជាដៃគូ៖ យើងនៅទីនេះដើម្បីជួយសំរួល និងជាជំនួយការរបស់រាល់អតិថិជនទាំងអស់ ដោយបានឃើញថាធនាគារយើងខ្ញុំជាដៃគូដ៏ល្អមួយដែលអតិថិជនរបស់យើងតែងតែមានភាពជឿទុកចិត្តបាន។
  - គុណភាពនៃសេវាកម្ម៖ យើងខិតខំស្វែងរកដំណោះស្រាយដើម្បីឆ្លើយតបចំពោះរាល់តម្រូវការសេវាកម្មធនាគារទាំងអស់។ យើងមានបំណងក្នុងការផ្តល់សេវាកម្មធនាគារប្រកបដោយទំនុកចិត្ត និងមានបច្ចេកវិទ្យាទំនើបបំផុតសំរាប់អតិថិជនកម្ពុជាទាំងអស់របស់យើង ពោលគឺក្នុងតួនាទីជាអ្នកជំនួយការ រឺគណនីអាជីវកម្មរបស់លោកអ្នក។
  - ការចូលរួមចំណែក៖ យើងមានបំណងធ្វើការចូលរួមចំណែកជាវិជ្ជមានដល់ប្រទេសកម្ពុជា។ យើងចង់ដើរតួនាទីដ៏មានអត្ថប្រយោជន៍នៅក្នុងជីវិតរបស់អតិថិជន។ យើងខ្ញុំ

ក៏ធ្វើការចូលរួមសកម្មភាពក្នុងសង្គមនានា ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ប្រទេសទាំងមូលផងដែរ។

- និរន្តរភាព និងភាពរីកចំរើន៖ យើងតែងតែគិតគូអំពីអនាគតរបស់ធនាគារយើង និងប្រជាជនកម្ពុជា ក៏ដូចជាប្រទេសកម្ពុជាយើងផងដែរ។ យើងខ្ញុំសូមបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតដូចគ្នាចំពោះបុគ្គលិក និងអតិថិជនរបស់យើងផងដែរ។ ទាំងអស់នេះហើយគឺជាវិធីសាស្ត្រមួយដែរនាំអោយយើងឈានទៅរកការធានាច្បាស់លាស់លើកំណើននៃធនាគារដែលមាននិរន្តរភាពមួយ។
- ក្រមសីលធម៌ និងសុជីវធម៌៖ យើងខ្ញុំពិតជាមានការយកចិត្តទុកដាក់លើការទទួលខុសត្រូវលើផ្នែកសង្គម និងប្រពៃណីរបស់ប្រទេសកម្ពុជា។ យើងអនុវត្តស្តង់ដារក្រមសីលធម៌ និងមានសុជីវធម៌ខ្ពស់រវាងគ្នានឹងគ្នា ព្រមទាំងអ្វីគ្រប់យ៉ាងដែលយើងកំពុងប្រតិបត្តិ ពោលគឺទាំងនៅក្នុងនិងក្រៅធនាគារ។

## ២.៦ រចនាសម្ព័ន្ធចាត់តាំងរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់

នៅក្នុងធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ សាខាស្ទឹងមានជ័យ មានបុគ្គលិក៖

- ប្រធានសាខា
- ប្រធានផ្នែកឥណទាន
- ប្រធានផ្នែកបេឡាករ
- ប្រធានផ្នែកទីប្រឹក្សាអតិថជន
- បេឡាករ
- ទីប្រឹក្សាអតិថជន
- មន្ត្រីឥណទានខ្នាតតូច
- មន្ត្រីឥណទាខ្នាតមធ្យម
- មន្ត្រីរដ្ឋាបាលឥណទាន
- មន្ត្រីរដ្ឋាបាលគណនី

## ២.៧. ផលិតផល និងសេវាកម្មរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់

### ២.៧.១ ប្រភេទគណនីសន្សំ

ធនាគារ ABA ផ្តល់ជូនផលិតផលជាច្រើនយ៉ាងទូលំទូលាយ ដែរបានរចនាឡើងដើម្បីផ្តល់អត្ថប្រយោជន៍ដល់គ្រប់វិស័យនៅក្នុងសហគមន៍កម្ពុជា ចាប់ពីប្រាក់កម្ចីអាជីវកម្មឥណទាន និង

គណនីចរន្ត រហូតដល់ប្រាក់បញ្ញើមានកាលកំណត់។ រាល់ផលិតផលដែលធនាគារ ABA ផ្តល់ជូន ត្រូវបានអនុម័តដោយប្រុងប្រយ័ត្នបមផុតដើម្បីស្របតាមតំរូវការទីផ្សារនៃប្រទេសកម្ពុជា។

➢ គណនីបញ្ញើបត់បែន

ជាមួយនឹងគណនីប្រាក់បញ្ញើបត់បែននៅធនាគារ ABA អ្នកអាចកាន់តែមានភាពងាយស្រួលចូលទៅប្រើប្រាស់ គណនីរបស់លោកអ្នកក្នុងការដក និងផ្ទេរប្រាក់ នៅពេលណាដែលលោកអ្នកចង់ និងនៅតែសន្សំអត្រាការប្រាក់ថេរខ្ពស់។

➢ បញ្ញើមានការកំណត់ ( Saving Account )

ធ្វើឱ្យប្រាក់របស់លោកអ្នកបង្កើនប្រាក់ចំណូលសម្រាប់លោកអ្នក ហើយដឹងច្បាស់អំពីចំនួនទឹក ប្រាក់ដែល លោកអ្នកនឹងទទួលបាន។ សូមជ្រើសរើសកាលកំណត់ដាក់ប្រាក់បញ្ញើរវាងពី 1 ទៅ 36 ខែនៅក្នុងគណនីបញ្ញើ មានកាលកំណត់ ដើម្បីទទួលបានការប្រាក់ក្នុងអត្រាប្រកួតប្រជែង។

➢ បញ្ញើសន្សំ

គណនីបញ្ញើសន្សំរបស់ធនាគារ ABA គឺជាមធ្យោបាយដ៏មានសុវត្ថិភាព និងមានប្រសិទ្ធផលបំផុតដើម្បីចាប់ផ្តើម សន្សំប្រាក់។

➢ គណនីចរន្ត ( Current Account )

គណនីចរន្តរបស់ធនាគារ ABA គឺជាវិធីដ៏សាមញ្ញ និង ងាយស្រួលមួយដើម្បីរីករាយជាមួយការទូទាត់ យ៉ាងងាយស្រួលសម្រាប់ការទិញទំនិញ និងសេវាកម្ម។

➢ គណនីចរន្ត "PLUS"

គណនីចរន្ត "PLUS" ផ្តល់លទ្ធភាពកាន់តែប្រសើរជូនលោកអ្នកក្នុងការចាប់ផ្តើមទទួលបានការប្រាក់ដោយប្រើប្រាស់គណនីចរន្តរបស់អ្នក។ ជាធម្មតា ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពថ្លៃចំណាយ ក្នុងការ គ្រប់គ្រងប្រាក់របស់លោកអ្នកនៅក្នុងប្រទេសកម្ពុជា ព្រមទាំងនៅបរទេស គណនីចរន្ត plus ផ្តល់កម្រិតងាយស្រួលលើសគេប្រកបដោយប្រសិទ្ធ ផលដ៏គួរឱ្យរីករាយ។

### ២.៧.២ ការផ្តល់ប្រាក់កម្ចី ឬឥណទាន

**➢ កម្ចីទាន់ចិត្ត**

អ្នកអាចដាក់ពាក្យស្នើសុំយកកម្ចីទាន់ចិត្តនិង ទទួលប្រាក់កម្ចីរហូតទៅដល់30,000

ដុល្លារ ដែលមានអត្រាការប្រាក់ដ៏ទាក់ទាញ និងរយៈពេលសងរហូតទៅដល់ 6ឆ្នាំ។

➢ **កម្ចីចម្រើនផល**

កម្ចីចម្រើនផល នឹងជួយឲ្យអាជីវកម្មលោកអ្នករីកចំរើន ដោយផ្តល់កម្ចីចាប់ពី 30,000 ដុល្លារ ដល់ 70,000ដុល្លារ ក្នុងអត្រាការប្រាក់ទាប រហូតដល់ 1.% ក្នុង1ខែ ហើយមានរយៈពេលវែងដល់ 8ឆ្នាំ ព្រមទាំងជួយទូទាត់ផ្តាច់កម្ចីដែលមានស្រាប់ផងដែរ។

លក្ខខណ្ឌអាចមានការផ្លាស់ប្តូរតាម សិទ្ធិរបស់ធនាគារដោយពុំមានការជូនដំណឹងជាមុនដល់អតិថិជនឡើយ។

➢ **ឥណទានអាជីវកម្ម**

បង្កើនភាពរីកចម្រើនសម្រាប់អាជីវកម្មរបស់លោកអ្នកដែរឬទេ? ចង់ស្វែងរកហិរញ្ញវត្ថុដែរឬទេ? ឥណទាន សហគ្រាសធុនតូច និងមធ្យមរបស់ធនាគារ ABA គឺជាប្រភពមួយយ៉ាងប្រសើរក្នុងការផ្តល់ឥណទានដើម្បីពង្រីក និងបង្កើតអាជីវកម្មថ្មី។

➢ **ឥណទានសាជីវកម្ម**

បង្កើនភាពរីកចម្រើនសម្រាប់អាជីវកម្មរបស់លោកអ្នកដោយប្រើកម្ចីក្រុមហ៊ុនរបស់ធនាគារ ABA។ យើងខ្ញុំនឹងជួយផ្តល់ប្រាក់ដើម្បីបំពេញកិច្ចសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសាជីវកម្មរបស់លោកអ្នក។

➢ **សេវាបង់ផ្តាច់កម្ចីចាស់**

នៅពេលពាក្យសុំស្នើសុំរបស់លោកអ្នកត្រូវបានទទួលយក លោកអ្នកអាចសងផ្តាច់ឥណទានបច្ចុប្បន្ន របស់លោកអ្នក រួមទាំងថ្លៃសងឥណទានមុនពេលកំណត់ និងមានឱកាសក្នុងការស្នើសុំឥណទានបន្ថែម ផងដែរ។ មន្ត្រីឥណទានប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំនឹងជួយនៅក្នុងដំណើរការផ្លាស់ប្តូរឥណទាន របស់លោកអ្នកពីគ្រឹះស្ថានហិរញ្ញវត្ថុពីមុនរបស់លោកអ្នកនៅក្នុងរយៈពេលមួយថ្ងៃធ្វើការ។

### ២.៧.៣ សេវាផ្ទេរប្រាក់

ធនាគារ ABA ផ្តល់ជូនសេវាផ្ទេរប្រាក់ទាំង ៣ ប្រភេទដូចខាងក្រោមសំរាប់បំពេញតាមទាំងតំរូវការផ្ទាល់ខ្លួន និងអាជីវកម្ម។ បណ្តាញទូទាត់អន្តរការីរបស់យើងទៅទូទាំងពិភពលោកធ្វើអោយយើងអាចធ្វើ និងទទួលបានមូលនិធិប្រកបដោយសុវត្ថិភាព ឆាប់រហ័ស និងដោយផ្ទាល់ទៅក្នុងគណនីធនាគារ ABA របស់លោកអ្នក។

- សេវាផ្ទេរប្រាក់ក្នុងស្រុក ( Domestic Transfer )៖ ជាមូលដ្ឋានសំរាប់ផ្ទេរមូលនិធិរវាងធនាគារ ABA និងធនាគារផ្សេងៗទៀតក្នុងប្រទេសកម្ពុជា។ យើងមានចំណងភាពជាដៃគូជាមួយធនាគារទាំងអស់នៅក្នុងប្រទេស ដូននេះហើយទើបទឹកប្រាក់របស់លោកអ្នកនឹងត្រូវបានផ្ទេរក្នុងរយៈពេលពេញមួយថ្ងៃធ្វើការ។
- សេវាផ្ទេរប្រាក់អន្តរជាតិ ( International Telegraphic Transfer )៖ ជាការផ្ទេរប្រាក់យ៉ាងឆាប់រហ័ស ចូលឬចេញក្រៅប្រទេសទាំងលក្ខណៈឯកជន ឬសាជីវកម្មតាមរយៈបណ្តាញធនាគារជាដៃគូទាំង១៦របស់ធនាគារ ABA។ ជាមួយនឹងការផ្ទេរប្រាក់តាមរយៈប្រព័ន្ធ SWIFT មូលនិធិរបស់លោកអ្នកនឹងត្រូវបានផ្ទេរដោយផ្ទាល់ទៅក្នុងគណនីរបស់អ្នកទទួលយ៉ាងឆាប់រហ័ស និងមានសុវត្ថិភាពបំផុត។ សំរាប់លេខកូដរបស់ធនាគារ ABA តាមរយៈប្រព័ន្ធ SWIFT គឺ ABAAKHPP។
- សេវាផ្ទេរប្រាក់អន្តរជាតិឆាប់រហ័ស ( International Instant Money Transfers )៖ ធនាគារ ABA គឺជាសមាជិកនៃប្រព័ន្ធផ្ទេរប្រាក់យ៉ាងឆាប់រហ័សផ្សេងៗគ្នាជាច្រើន។ គិតត្រឹមខែសីហា ឆ្នាំ២០១៤ ធនាគារ ABA បានចូលរួមនៅក្នុងការផ្ទេរប្រាក់តាមប្រព័ន្ធ MoneyGram, MoneyGrado, DBP Remittance, GCash និងIME Money Transfer។

### ២.៧.៤ លិខិតធានារបស់ធនាគារ

លិខិតធានារបស់ធនាគារ គឺជាគឺការសន្យាធានាជាលាយលក្ខណ៍អក្សរដែលមិនអាចលុបចោលបានរបស់ធនាគារដើម្បីទូទាត់ប្រាក់ទៅអោយអ្នកទទួលផល ប្រសិនបើកាតព្វកិច្ចរបស់អ្នកដាក់ពាក្យសុំមិនត្រូវបានបំពេញ ឬបំពេញមិនបានពេញលេញ។ ធនាគារ ABA ត្រៀមខ្លួនរួចជាស្រេចក្នុងការចេញលិខិតធានាដូចខាងក្រោម៖

- លិខិតធានាលើការដេញថ្លៃ ( Bid Bonds )
- លិខិតធានាលើការទូទាត់ ( Performance Bonds )
- លិខិតធានាលើការអនុវត្តកិច្ចសន្យា ( Advanced Payment Guarantee )
- លិខិតធានាលើការបុរេប្រទាន ( Payment Guarantee )

### ២.៧.៥ ហិរញ្ញប្បទានពាណិជ្ជកម្ម(Trade Finance)

ធនាគារ ABA ផ្តល់នូវរបៀបទូទាត់ប្រាក់ផ្សេងៗគ្នា និងលិខិតូបករណ៍ជាច្រើនដែលប្រើប្រាស់នៅក្នុងប្រតិបត្តិការនាំចេញ និងនាំចូលអន្តរជាតិ ដើម្បីកាត់បន្ថយហានិភ័យទាំងសំរាប់អ្នក

ទិញ និងអ្នកលក់។ ធនាគារយើងខ្ញុំត្រៀមផ្តល់អោយលោកអ្នកនូវដំណោះស្រាយដើម្បីគាំទ្រ និងពង្រីកអាជីវកម្មអន្តរជាតិរបស់លោកអ្នក។ សេវារបស់យើងរួមមាន៖

- ការចេញលិខិតឥណទាន ( Letters of Credit )
- លិខិតឥណទានអចិន្ត្រៃយ៍ ( Standby Letters of Credit )
- លិខិតូបករណ៍ហិរញ្ញវត្ថុពាណិជ្ជកម្មផ្សេងៗទៀត។

**២.៧.៦ ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន**(Payment Cards(Debit Card, Credit cards)

ធនាគារ ABA មានគ្រប់ប្រភេទប័ណ្ណឥណទាន និងប័ណ្ណឥណពន្ធដែលបានរចនាឡើងដើម្បីបំពេញតាមតំរូវការដ៏ទាន់សម័យរបស់ប្រជាជនកម្ពុជា ដែររួមមានចាប់ពីប័ណ្ណ ATM ធម្មតារហូតដល់ប័ណ្ណ GOLD ។ ថ្លៃសេវាប្រតិបត្តិការផ្ទេរទាប និងគំរោងបញ្ចុះតំលៃដ៏គួរអោយទាក់ទាញគឺគ្រាន់តែជាសេវាបន្ថែមដែលមានសំរាប់អតិថិជនដែលកាន់ប័ណ្ណរបស់ធនាគារ ABA យើងខ្ញុំប៉ុណ្ណោះ។

- ប័ណ្ណឥណពន្ធ ( Debit Cards ) សំរាប់ប័ណ្ណឥណពន្ធអន្តរជាតិ ( MasterCard ) និង Visa អាចប្រើប្រាស់ជាមួយម៉ាស៊ីន ATM ទាំងក្នុង និងក្រៅប្រទេសក្នុងការដកសាច់ប្រាក់ និងសំរាប់ការទិញទំនិញ និងសេវាកម្មផ្សេងៗប្រចាំថ្ងៃ។ ប័ណ្ណ MasterCard និង Visa អន្តរជាតិក៏អាចប្រើប្រាស់បាននៅលើ Paypal សំរាប់រាល់ការទូទាត់នៅលើបណ្តាញអ៊ិនធឺណេតផងដែរ។
- ប័ណ្ណឥណទាន ( Credit Card ) ធនាគារ ABA បានចេញប័ណ្ណឥណទានអន្តរជាតិ MasterCard និង Visa ដែលផ្តល់នូវអាទិភាពដ៏សំខាន់ក្នុងការប្រើប្រាស់ទឹកប្រាក់របស់ធនាគារនៅពេលដែរអ្នកត្រូវការជាបន្ទាន់។ អតិថិជនដែលបានបើកនូវគណនីចរន្ត គណនីសន្សំ គណនីបញ្ញើមានកាលកំណត់ ឫគណនីបញ្ញើបត់បែនរបស់ធនាគារ ABA ក្នុងចំនួនទឹកប្រាក់អប្បបរមា ៣,០០០.០០ ដុល្លារអាមេរិក នឹងមានសិទ្ធិទទួលបានប័ណ្ណឥណទានដោយឥតគិតថ្លៃ។ កម្រិតឥណទានអាចត្រូវបានកំណត់ចាប់ពី ៥០០.០០ ដុល្លារអាមេរិករហូតដល់ទៅ ៩០% នៃចំនួនប្រាក់បញ្ញើដែលបានបង្ខាំងទុក។

**២.៧.៧ សេវាបើកប្រាក់បៀវត្សរ៍** (Payroll Service)

សេវាបើកប្រាក់បៀវត្សរ៍ ( Payroll Service ) របស់ធនាគារយើងខ្ញុំផ្តល់ឱកាសប្រសើរបំផុតសំរាប់ជួយសំរួលដល់អាជីវកម្មដែលមានបុគ្គលិកច្រើន ដោយអាចកាត់បន្ថយថ្លៃចំណាយ កាត់

បន្ថយដំណើរការងារឯកសារ និងបង្កើនសុវត្ថិភាព។ ដូច្នេះលោកអ្នកមិនចាំបាច់ដកសាច់ប្រាក់ពីគណនីសារជីវកម្ម ឬចេញមូលប្បទានបត្រទៀតឡើយ។ ជាផ្នែកមួយនៃគំរោងបើកប្រាក់បៀវត្សរ៍ដោយយើងខ្ញុំនឹងចេញប័ណ្ណ ATM ដោយឥតគិតថ្លៃជូនទៅបុគ្គលិករបស់អ្នក ក្នុងគោលបំណងដើម្បីអោយពួកគាត់អាចប្រើប្រាស់មូលនិធិរបស់ខ្លួនបានភ្លាមក្នុងរយៈពេល ២៤ម៉ោង ក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយសប្តាហ៍តាមរយៈបណ្តាញម៉ាស៊ីន ATM របស់ធនាគាររបស់យើង។

## ២.៨ វប្បធម៌ការងាររបស់ធនាគារខេមបូឌាន: អាស៊ីចំកាត់

### ២.៨.១ ពេលវេលាបម្រើការងារ

- ត្រូវបំពេញការងារចំនួន ៤៥ (សែសិបប្រាំម៉ោង) ក្នុងមួយសប្តាហ៍ ដោយធ្វើការងារចំនួន ៥ (ប្រាំ) ថ្ងៃកន្លះជាប់គ្នាក្នុងមួយសប្តាហ៍។
- ចាប់ផ្តើមធ្វើការចាប់ពីម៉ោង ៨:០០ ព្រឹកដល់ម៉ោង ៥:០០ ល្ងាចដោយមានពេលសម្រាកទទួលទានអាហារថ្ងៃត្រង់ចំនួនម៉ោង។
- បុគ្គលិកត្រូវបានចាត់តាំងឲ្យធ្វើការងារក្នុងវេនផ្សេងៗគ្នាស្របទៅតាមលក្ខណអាជីវកម្ម ឬ កិច្ចសន្យា។

### ២.៨.២ សុជីវធម៌ និងចរិយាមាយាទ

ការគួរសមដែលបង្ហាញអំពីការគោរព និងឥរិយាបថល្អមានសារៈសំខាន់ណាស់។ សូមមានការគោរពបង្ហាញអំពីការយកចិត្តទុកដាក់ និងចេះគិតគូរដល់អ្នកដទៃ។

- ត្រូវអត់ធ្មត់ ចិត្តល្អ និងបង្ហាញឥរិយាបថរីករាយ
- ត្រូវស្អាតជានិច្ច ដូចជាការស្លៀកសំលៀកបំពាក់ ឬឯកសណ្ឋានដែលមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់។
- មិនត្រូវមានចរិតក្រអឺតក្រទម ឬជេរប្រមាថមើលងាយអតិថិជន ឬសហការីរបស់អ្នកឡើយ
- បុគ្គលិកអាចអានសារព័ត៌មាន ក្នុងម៉ោងធ្វើការប្រសិននេះគឺជាការងារទូទៅ ឬពាក់ព័ន្ធនឹងការងាររបស់អ្នក។
- មិនត្រូវអានកាសែត លេងហ្គេម ឬប្រើប្រាស់បណ្តាញសង្គម ឬស្តាប់ប្រព័ន្ធផ្សព្វផ្សាយ

  ប្រភេទណាមួយឡើយ ប្រសិនបើអ្នកគឺជាបុគ្គលិកប្រាស្រ័យទាក់ទងផ្ទាល់ជាមួយអតិថិជន
- មិនត្រូវផ្តល់ចម្លើយអតិថិជន ដូចជា "ខ្ញុំមិនដឹង ខ្ញុំជាប់រវល់ ។ល។" ត្រូវស្នើរសុំជំនួយពីប្រធានផ្ទាល់របស់អ្នក ប្រសិនបើអ្នកមិនអាចដោះស្រាយ ឬឆ្លើយតបនឹងសំណើរ ឬសំណួរ

របស់អតិថិជនបាន។

### ២.៨.៣ ឥរិយាបថនៅកន្លែងការងារ

ត្រូវមានការគោរពគ្នាទៅវិញទៅមក ប្រកបដោយសេចក្តីថ្លៃថ្នូរ ហើយមិនត្រូវមានការរើសអើងណាមួយឡើយ។ យើងរំពឹងថាអ្នកនឹងបំពេញតាមស្តង់ដារសង្គមដែលអាចទទួលយកបាន ហើយរំពឹងថាអ្នកនឹងចូលរួមចំណែកក្នុងបរិយាកាសការងារដ៏វិជ្ជមាន និងមានសុវត្ថិភាព។

- ការសន្ទនាដែលពាក់ព័ន្ធនឹងការងារ គួរតែធ្វើឡើងដាច់ដោយលែក។ ការសន្ទនាប្រភេទនេះមិនគួរធ្វើអោយរំខានដល់ការផ្តល់សេវាកម្មរបស់អ្នកជូនអតិថិជនឡើយ។
- ចាំបាច់គួរចៀសវាងការសន្ទនាលឺៗ។
- មិនត្រូវពិភាក្សា ឫផ្តល់មតិយោបល់នៅទីសាធារណៈអំពីអតិថិជន ឫអំពីមិត្តរួមការងារដ៏ទៃទៀតឡើយ ដែលអាចអោយអតិថិជន ឫមិត្តរួមការងារស្តាប់លឺដោយចៃដន្យ។
- ត្រូវត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយតបនឹងសំណើរណាមួយពីអតិថិជន ឫពីថ្នាក់ដឹកនាំកំពូល។
- តបហូរស្វាគមន៍ជានិច្ចចំពោះអតិថិជនដោយដាក់សារព័ត៌មានសំរាប់អាន ទឹកតែ ឫកាហ្វេ ហើយមិនត្រូវទុកភ្ញៀវចោលតែឯងឡើយ។
- ការបរិភោគត្រូវហាមជាដាច់ខាតនៅកន្លែងបំរើសេវាកម្មអតិថិជន។ ការទទួលទានភេសជ្ជៈត្រូវបានអនុញ្ញាត ប៉ុន្តែគួរដាក់ភេសជ្ជៈនោះកុំអោយដួលកំពប់ ហើយត្រូវប្រាកត់ថាសំភារៈការិយាល័យត្រូវបានការពារត្រឹមត្រូវ។

### ២.៨.៤ ការប្រាស្រ័យទាក់ទង និងការបង្ហាប់បញ្ជា

ការប្រាស្រ័យទាក់ទង គឺជាកត្តាចាំបាច់រវាងសមាជិកការងារនៅក្នុងមុខតំណែង និងកំរិតគ្រប់គ្រងផ្សេងៗ។ ការប្រាស្រ័យទាក់ទងល្អរួមនឹងស្តង់ដារក្រមសីលធម៌ខ្ពស់ គឺជាវិធីធ្វើការងាររបស់ធនាគារ ABA ។ ការអនុវត្តតាមវិធីទាំងនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើនកំរិតជឿទុកចិត្ត និងការគាំទ្រចំពោះគ្នាទៅវិញទៅមក។

- អ្នកមិនត្រូវផ្ញើសារអេឡិចត្រូនិច ឫហៅទូរស័ព្ទ ឫដាក់ឯកសារជូនថ្នាក់ដឹកនាំដោយគ្មានការអនុញ្ញាតពីប្រធានអ្នកនោះឡើយ
- អ្នកអាចប្រាស្រ័យទាក់ទងជាមួយថ្នាក់ដឹកនាំដោយផ្ទាល់បានក្នុងករណីដែលអ្នកត្រូវបានចាត់តាំងធ្វើការងារនោះ ឫប្រសិនបើអ្នកត្រូវបានចាត់តាំងអោយរាយការដោយផ្ទាល់

- ក្នុងករណីមានវិវាទ ឬមានការពិបាកក្នុងការរាយការណ៍បញ្ហាណាមួយទៅប្រធានផ្ទាល់របស់អ្នក អ្នកអាចរាយការណ៍ទៅប្រធាននាយកដ្ឋានធនធានមនុស្សបាន។

# ជំពូកទី ៣
# ការផ្តល់ឥណទានរបស់
# ធនាគារ ឧឡូន: អាស៊ី
# ចំកាត់

# ជំពូកទី៣

# ការផ្តល់ឥណទានរបស់ធនាគារវឌ្ឍៈ អាស៊ី ចំកាត់

## ៣.១ លក្ខណៈទូទៅឥណទាន

### ៣.១.១ និយមន័យឥណទាន

ឥណទាន គឺជាការផ្តល់កម្ចីដល់សាធារណៈជនក្នុងរយៈពេលជាក់លាក់ណាមួយ និង ប្រមូលត្រលប់មកវិញទាំងប្រាក់ដើម និងការប្រាក់តាមកិច្ចសន្យាដែលបានកំណត់។

## ៣.២ ការចាត់ថ្នាក់ឥណទាន

ចំពោះវិស័យឥណទានធនាគារវឌ្ឍៈ អាស៊ី ចំកាត់ បានចាត់ថ្នាក់ឥណទានជាបួន រួមមាន៖

- គ្រឹះស្ថានហិរញ្ញវត្ថុ (Financial Institution)
  - ធនាគារជាតិ (Central Bank)
  - គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ(Depository Institutions)
  - គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត (Other financial institutions)
- គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ(Non-Financial Institution)
  - កសិកម្ម, រុក្ខាប្រម៉ាញ់, និងនេសាទ(Agriculture, forestry and fishing)
  - រ៉ែ និងបូមបច្ចជីក(Mining and Quarrying)
  - កម្មន្តសាលកម្ម(Manufacturing)
  - ការផ្គត់ផ្គង់សេវាសាធារណៈ(Utilities)
  - សំណង់(Construction Services)
  - ការជួញដូរដុំ(Wholesale Trade)
  - ការជួញដូររាយ(Retail Trade)
  - សណ្ឋាគារនិងភោជនីយដ្ឋាន(Hotel and restaurants)
  - ដឹកជញ្ជូននិងស្តុកបណ្តោះអាសន្ន(Transportation and storage)
  - បណ្តាញព័ត៌មាននិងទូគមនាគមន៍(Information Media & Telecommunication)
  - អាជីវកម្មជួល និងភតិសន្យា(Renting and Leasing)
  - ការជួញដូរអចលនទ្រព្យ(Real estate activities)
  - សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត(Other Non-Financial Services)

- តម្រូវការផ្ទាល់ខ្លួន(Personal Essential)
  - ការឲ្យខ្ចីជាបុគ្គល(Personal Lending)ខ
  - ការឲ្យខ្ចីតាមប័ណ្ណឥណទាន(Credit Cards)
  - ការឲ្យខ្ចីទិញផ្ទះ(Mortgages)
- ឥណទានផ្សេងៗទៀត(Other Lending) : វិស័យផ្សេងៗទៀតដែលមិនមានរៀបរាប់ខាងលើ

## ៣.៣ ប្រភេទឥណទាន

នៅធនាគារវឌ្ឍនៈ អាស៊ីចំកាត់បានបែងចែកប្រភេទឥណទានជាប្រាំប្រភេទដូចខាងក្រោម

- **កម្ចីទាន់ចិត្ត**

អតិថជនអាចដាក់ពាក្យស្នើសុំយកកម្ចីទាន់ចិត្ត និងទទួលប្រាក់កម្ចីរហូតទៅដល់ 30,000 ដុល្លារ ដែលមានអត្រាការប្រាក់ដ៏ទាក់ទាញ និងរយៈពេលសងរហូតទៅដល់ 6ឆ្នាំ។

- **កម្ចីចម្រើនផល**

កម្ចីចម្រើនផល នឹងជួយឲ្យអាជីវកម្មអតិថជនរីកចំរើន ដោយផ្តល់កម្ចីចាប់ពី 30,000 ដុល្លារ ដល់ 70,000ដុល្លារ ក្នុងអត្រាការប្រាក់ទាប រហូតដល់ 1.% ក្នុង1ខែ ហើយមានរយៈពេលវែងដល់ 8ឆ្នាំ ព្រមទាំងជួយទូទាត់ផ្តាច់កម្ចីដែលមានស្រាប់ផងដែរ។
លក្ខខណ្ឌអាចមានការផ្លាស់ប្តូរតាម សិទ្ធិរបស់ធនាគារដោយពុំមានការជូនដំណឹងជាមុនដល់អតិថិជនឡើយ។

- **ឥណទានអាជីវកម្ម**

បង្កើនភាពរីកចម្រើនសម្រាប់អាជីវកម្មរបស់លោកអ្នកដែរឬទេ? ចង់ស្វែងរកហិរញ្ញវត្ថុដែរឬទេ? ឥណទាន សហគ្រាសធុនតូច និងមធ្យមរបស់ធនាគារ ABA គឺជាប្រភពមួយយ៉ាងប្រសើរក្នុងការផ្តល់ឥណទានដើម្បីពង្រីក និងបង្កើតអាជីវកម្មថ្មី។

- **ឥណទានសាជីវកម្ម**

បង្កើនភាពរីកចម្រើនសម្រាប់អាជីវកម្មរបស់អតិថជនដោយប្រើកម្ចីក្រុមហ៊ុនរបស់ធនាគារ ABA។ ធនាគរវឌ្ឍនៈ អាស៊ី ចំកាត់ នឹងជួយផ្តល់ប្រាក់ដើម្បីបំពេញកិច្ចសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសាជីវកម្មរបស់អតិថិជន។

➢ **សេវាបង់ផ្តាច់កម្ចីចាស់**

នៅពេលពាក្យសុំស្នើសុំរបស់អតិថិជនត្រូវបានទទួលយក អតិថិជនអាចសងផ្តាច់ឥណទានបច្ចុប្បន្ន របស់ពួកគាត់ រួមទាំងថ្លៃសងឥណទានមុនពេលកំណត់ និងមានឱកាសក្នុងការស្នើសុំឥណទានបន្ថែម ផងដែរ។ មន្ត្រីឥណទានប្រកបដោយវិជ្ជាជីវៈរបស់ធនាគារនឹងជួយនៅក្នុងដំណើរការផ្លាស់ប្តូរឥណទាន របស់អតិថជនពីគ្រឹះស្ថានហិរញ្ញវត្ថុពីមុនរបស់អតិថជននៅក្នុងរយៈពេលមួយថ្ងៃធ្វើការ។

## ៣.៤ លក្ខខណ្ឌក្នុងការផ្តល់ឥណទាន

### ៣.៤.១ ការវិភាគលើ៥Rs

តាមរយៈការចុះសិក្សាស្រាវជ្រាវផ្ទាល់នៅធនាគារវឌ្ឍនៈ អាស៊ីចំកាត់ សង្កេតឃើញថាធនាគារបានវិភាគទៅលើអតិថជន មុននិងផ្តល់ឥណទានដូចខាងក្រោមៈ

- Right Person ( ការផ្តល់ចំមនុស្សត្រឹមត្រូវ)

➢ ចរិកលក្ខណៈ (Character)

- អត្តចរិកល្អ, សុចរឹត, ទៀងត្រង់
- មានអំណត់អត់ធន់ ព្យាយាម ឧស្សាហ៍
- ប្រវត្តរស់នៅក្នុងសង្គម (Social Record)

➢ មានកេរ្តិ៍ឈ្មោះល្អ

- មានទំនាក់ទំនងល្អ
- មានវប្បធម៌ល្អក្នុងការរស់នៅ
- មានជំនាញ បទពិសោធន៍លើមុខរបរ

➢ ការទទួលខុសត្រូវ (Responsibility)

- មានសេចក្តីអង់អាចក្នុងការងារ
- ការប្តេជ្ញាចិត្តខ្ពស់ក្នុងការសងបំណុល ការធានា

➢ សុខភាព (Health)

- សុខភាពរឹងមាំគ្មានជំងឺរ៉ាំរ៉ៃ

- Right Business (ការផ្តល់ឥណទានចំមុខរបរដែលមានសក្តានុពល)

ភ្នាក់ងារឥណទានត្រូវស្វែងយល់ និងវិភាគទៅលើមុខរបររបស់អតិថជនដូចខាងក្រោម៖

- ប្រភេទនៃមុខរបរ ប្រវត្តនៃមុខរបរ
- ពិនិត្យមើលប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង
- ពិនិត្យមើលអ្នកជំនាញ
- ពិនិត្យលើប្រព័ន្ធដំណើរការ និងស្ថានភាពហិរញ្ញវត្ថុ

- Right Amount (សមត្ថភាពសង)

  សមត្ថភាពសងអាចកើនឡើងស្របទៅ និងការជឿជាក់របស់ភ្នាក់ងារឥណទានមានកំរិតណាក្រោយពីបានធ្វើការប្រមូលព័ត៌មាន និងបានធ្វើការវាយតំលៃពីការផ្តល់ប្រាក់កម្ចីរួច។

- Right Time (ការផ្តល់កម្ចីត្រូវពេលវេលា)

  ក្នុងការផ្តល់ឥណទាន ត្រូវបានធ្វើឡើងទៅតាមរដូវកាលនៃការចាប់ផ្តើមផ្តល់ឥណទាន និងត្រូវកំណត់កាលបរិច្ឆេទឲ្យមានច្បាស់ និងអនុវត្តទៅតាមការកំណត់ក្នុងការប្រមូលទុនត្រឡប់មកវិញ។ ផ្តល់ទុន និងកំណត់រយៈពេលត្រូវឲ្យសមស្របទៅតាមរយៈពេលនៃការប្រកបមុខរបរ

ផ្តល់ទុនត្រូវពេលតាមតម្រូវការនៃមុខរបរ។

### ៣.៤.២ ការវិភាគលើ៥Cs

ឆ្លងតាមការចុះកម្មសិក្សា ព្រមទាំងការសាកសួរពីមន្រ្តីឥណទាននៅក្នុងធនាគារវឌ្ឍនៈអាស៊ី ចំកាត់រួចមក យើងឃើញថាធនាគារបានវិភាគអតិថជនទៅលើ៥Cs ដូចជា៖

- អត្តចរិក(Character)
  - ប្រវត្តិនៃការរស់នៅ
  - ប្រវត្តនៃការសងត្រលប់
  - កេរ្តិ៍ឈ្មោះ
  - ភាពស្មោះត្រង់ និងទំនួលខុសត្រូវ។
- សម្តតភាព(Capacity)
  - ពិនិត្យលើផ្លូវច្បាប់ថាអតិថជនអាចស្នើសុំកម្ចីស្របច្បាប់ដែរឬទេ និងមានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែរឬទេ?

- មានលិទ្ធភាពសងត្រលប់មកវិញចាប់បី៧០%ឡើងទៅ

- ដើមទុន(Capital)
  - ទ្រព្យសកម្ម
  - ទ្រព្យអសកម្ម
  - ទុនបម្រុង
  - ចំណូលបន្ថែម
- ទ្រព្យធានា ប្លង់រឹង ឬប្លង់ទន់
- លក្ខខណ្ឌ
  - លក្ខខណ្ឌអាជីវកម្ម(ផលិតផល, សេវាកម្ម, ពាណិជ្ជកម្ម,នីត្យានុកូលភាព, ទីតាំង, តម្លៃ, ទីផ្សារ, ការប្រកួតប្រជែង)
  - លក្ខខណ្ឌធម្មជាតិ
  - លក្ខខណ្ឌសេដ្ឋកិច្ច
  - លក្ខខណ្ឌនយោបាយ
  - លក្ខខណ្ឌសង្គម

### ៣.៤.៣ ដំណើរការនៃការផ្តល់ឥណទាន

មុនផ្តល់ឥណទានឲ្យដល់អតិថជននៅធនាគារវឌ្ឍនៈ អាស៊ីចំកាត់មន្ត្រីឥណទានទាំងអស់ត្រូវអនុវត្តតាមជំហានទាំងដប់ដូចជា៖

**ជំហានទី១** ប្រមូលពត៌មាន

- ទទួលពាក្យស្នើសុំខ្ចីពីអតិថជន
- ប្រមូលឯកសារដែលពាក់ព័ន្ធដូចជាអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ.....។
- លិខិតយល់ព្រមឲ្យឆែកCBC

**ជំហានទី២** ឆែកCBC ដើម្បីឆែកCBC ត្រូវមានឯកសារដូចជា ពាក្យស្នើសុំកម្ចី អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន និងលិខិតយល់ព្រមរបស់អតិថជន។

**ជំហានទី៣** រៀបចំការវិភាគហិរញ្ញវត្ថុនិងCAR

- ថតចំលងឬ ស្កេនឯកសារដែលពាក់ព័ន្ធ
- របាយការណ៍នៃការចុះទៅពិនិត្យដល់ទីកន្លែងមានដូចជា កន្លែងធ្វើការ ប្លង់និង

  កន្លែងរស់នៅ។

- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងCAR

**ជំហានទី៤** គណៈកម្មាការឥណទាន ៖ មន្ត្រីឥណទានត្រូវស្នើសុំការផ្តល់កម្ចីដោយបញ្ជូនឯកសារដូចជា៖

- បំពេញពាក្យស្នើសុំកម្ចី
- របាយការណ៍ដែលបានចុះទៅពិនិត្យដល់កន្លែងផ្ទាល់
- ឯកសារវាយតម្លៃទ្រព្យធានា
- របាយការណ៍ហិរញ្ញវត្ថុ
- ឯកសារផ្លូវច្បាប់
- របាយការណ៍CBC
- ឯកសារដែលពាក់ពន្ធទាំងអស់

**ជំហានទី៥** រៀបចំឯកសារច្បាប់៖ ក្នុងករណីដែលទទួលបានការយល់ព្រមផ្តល់កម្ចីពី CCMBL រួចហើយSMLO និងរៀបចំឯកសារច្បាប់ដូចជា៖

- ពាក្យសុំខ្ចីប្រាក់
- កិច្ចសន្យាបរិភោគ
- កិច្ចសន្យាហ៊ីប៉ូតែក
- លិខិតធានា
- លិខិតបញ្ជាក់ការយល់ព្រម
- កិច្ចសន្យាផ្សេងទៀតអាស្រ័យទៅតាមប្រភេទកម្ចី

បន្ទាប់មកផ្ញើរឯកសារទាំងអស់តាមរយៈអ៊ីម៉ែលទៅការិយាល័យកណ្តាលដើម្បីត្រួតពិនិត្យ ហើយអ្នកជំនាញខាងច្បាប់បានបញ្ជាក់ថាត្រឹមត្រូវនឹងផ្ញើរត្រលប់មកវិញដើម្បីឲ្យភ្ញៀវផ្តិតមេដៃលើឯកសារទាំងអស់។

**ជំហានទី៦** ផ្តិតមេដៃ និងបើកគណនី៖ ត្រូវអញ្ជើញភ្ញៀវមកផ្តិតមេដៃ និងណែនាំភ្ញៀវទៅជួបជាមួយអ្នកប្រឹក្សាអតិថជនដើម្បីបើកគណនី។

**ជំហានទី៧** ការចុះបញ្ជីបង្កើតហ៊ីតែក៖ MBLO និងអតិថជនយកប្លង់រឹងច្បាប់ដើមនិងឯកសារច្បាប់ទៅចុះបញ្ជីជាមួយអាជ្ញាធរ។ ហើយត្រូវយកប្លង់នោះរក្សាទុកក្នុងទូរដែកបន្ទាប់មកត្រូវកត់ត្រាចូលក្នុងប្រព័ន្ធ(Post collateral in Flex tools)

**ជំហានទី៨** ការកត់ត្រាប្លង់(Post Collateral) បន្ទាប់ពីបានចុះបញ្ជីប្លង់រឹងច្បាប់ដើម SMLO ត្រូវកត់ត្រាចូលក្នុងFlex tools.

**ជំហានទី៩** ការទំលាក់កម្ចី៖ ក្នុងជំណាក់កាលនេះត្រូវស្កេនឯកសាច្បាប់ទាំងអស់ ប្លង់ លិខិតបញ្ជាក់ការអនុញ្ញាតផ្តល់កម្ចី និងឯកសារដែលពាក់ព័ន្ធផ្សេងទៀតផ្ញើរទៅ Legal Department បើសិនកម្ចីស្មើឬលើសពី២០០០០០ បើសិនកម្ចីក្រោម២០០០០០ត្រូវផ្ញើរទៅ Credit Operation Officer។ បន្ទាប់ពីទទួលបានព័ត៌មានពីការិយាល័យកណ្តាលថាកម្ចីត្រូវបានទំលាក់ ត្រូវយកតារាងសងប្រាក់ និលិខិតបញ្ជាក់ការទំលាក់កម្ចី រួចហើយផ្តល់ដំណឹងទៅអតិថជនដើម្បីឲ្យគាត់ដកប្រាក់។ ហើយត្រូវរៀបចំឯកសារ កិច្ចសន្យាខ្ចី កិច្ចសន្យាហ៊ីប៉ូតែក លិខិតធានា តារាងសងប្រាក់ និងលិខិតបញ្ជាក់ការទំលាក់កម្ចីទៅអតិថជន។

**ជំហានទី១០** ការទុកដាក់ឯកសាកម្ចី៖ LADM ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំទុកដាក់ឯកសារកម្ចី ហើយត្រូវរៀបឯកសារកម្ចីតាមលំដាប់ដូចជា៖

- ព័ត៌មានក្នុងការទំលាក់កម្ចី
- ព័ត៌មានក្នុងការវាយតម្លៃ
- កិច្ចសន្យា
- ឯកសារដែលពាក់ព័ន្ធ
- ព័ត៌មានរបស់ក្រុមហ៊ុនឬ អ្នកខ្ចី
- ព័ត៌មានត្រួតពិនិត្យនិង សន្តិសុខ។

### ៣.៤.៤ ទ្រព្យធានាដែលអាចទទួលយកបាន

ចំពោះទ្រព្យធានា នៅធានាគារវឌ្ឍន: អាស៊ីចំកាត់ អាចទទួលយកបានដូចជា៖

- អចលនទ្រព្យប្លង់រឹង ឬ ប្លង់ទន់(ត្រូវតែមានសម្រាប់ប្រាក់កម្ចីខ្នាតតូចទាំងអស់)
- អចលនទ្រព្យរបស់ភាគគីទី៣, របស់សហពានិជ្ជ និងប័ណ្ណធានាពីធនាគារ
- វត្ថុធានាផ្សេងទៀតអាចចចារជាមួយធានាគារបាន៖
    - Fixed Deposit (ប្រាក់បញ្ញើរមានកាលកំណត់)
    - STD cut from HTD(ប្លង់ទន់កាត់ចេញពីប្លង់)
    - Vehicles (យានយន្ត)
    - Machineries (ម៉ាស៊ីមានទ្រង់ទ្រាយធ្យម)

- Trade Stocks(វិក័យប័ត្រទំនិញដែលមានតំលៃខ្ពស់)
- ប្លង់គូបរបស់អ្នកស្នើរសុំខ្ចី(បញ្ជីឈ្មោះផ្សារ ដែលមានប្លង់គូបអាចទទួលយកបានត្រូវអនុម័ត និងធ្វើបច្ចុប្បន្នភាពដោយគណកម្មការឥណទានការរយាល័យកណ្តាលតាមដំណាក់កាល) ច្បាប់ចតចំលងប្លង់រឹង និងទន់របស់ថអ្នកខ្ចីគួរភ្ជាប់ជាឯកសារយោង។

**ចំណាំ**

– មិនគួរផ្តល់ប្រាក់កម្ចីជូនភ្ញៀវ ដែលមករកខ្ចីដល់ធនាគារដោយមានតែប្លង់ទន់។ ធនាគារនឹងពិចារណាយ៉ាងហ្មត់ចត់ មុននឹងផ្តល់ប្រាក់កំចីជូនភ្ញៀវបែបនេះដោយផ្អែកលើកេរ្តិ៍ឈ្មោះ និងតំលៃឥណទានល្អ។

– ប្លង់ទន់ទាំងអស់ត្រូវមានព្រំប្រទល់ និងទំហំច្បាស់លាស់នៅក្នុងឯកសារបញ្ជាក់កម្មសិទ្ធិ។

- ប្រាក់កម្ចីធៀបនឹង ទ្រព្យធានា[27]

| ប្រភេទទ្រព្យ | ផលធៀបពីមុន | ប្តូរថ្មី |
|---|---|---|
| ដីគេហដ្ឋាន+ផ្ទះទីតាំងធ្វើជំនួញ រោងចក្រ (ប្លង់រឹង ឬ ទុន) | ៥0% នៃតំលៃទ្រព្យដែលវាយតំលៃដោយធនាគារ | ៦0% នៃតំលៃទ្រព្យដែលវាយតំលៃដោយធនាគារ |
| រាល់ទ្រព្យដែលជាដីកសិកម្ម (ប្លង់រឹង ឬ ទុន) | ៤0% នៃតំលៃទ្រព្យដែលវាយតំលៃដោយធនាគារ | ៥0% នៃតំលៃទ្រព្យដែលវាយតំលៃដោយធនាគារ |

តារាងទី១

- ចំនួនទឹកប្រាក់កម្ចី[28]

| ប្លង់រឹង និងប្លង់ទន់ | | ប្លង់គូប | |
|---|---|---|---|
| ចំនួនតិចបំផុត | ១.000ដុល្លារ | ចំនួនតិចបំផុត | ១.000ដុល្លារ |
| ចំនួនច្រើនបំផុត | ៧0.000ដុល្លារ | ចំនួនតិចបំផុត | ១៥.000ដុល្លារ |

តារាងទី២

- រូបិយវត្ថុ

យើងផ្តល់កម្ចីជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល

- ឥណទាន[29]

[27] តួនាទី និងការទទួលខុសត្រូវរបស់មន្រ្តីឥណទានភាគ១, ២០១៦ ទំព័រ៣០

[28] តួនាទី និងការទទួលខុសត្រូវរបស់មន្រ្តីឥណទានភាគ១, ២០១៦ ទំព័រ៣១

| ឥណទាន | ឥណទានរយៈពេលខ្លី (Loan ≤ 12 months )<br>ឥណទានរយៈពេលវែង (Loan ≥ 12 months) |
|---|---|

តារាងទី៣

## ៣.៥ ការគណនាការប្រាក់[30]

| Loan Amount In USD | Interest Rate(P.a) (Strong Title) | Interest Rate(P.a) (Soft Title) | Interest Rate (P.a) Store Ownership | Maximum Tenure | Processing Fees |
|---|---|---|---|---|---|
| 1,000-5,000 | 15.60% and above | 16.80% and above | 18.00% and above | 36 months | 0% |
| >5,000-10,000 | 14.40% and above | 15.60% and above | 16.80% and above | 60 months | 0.50% |
| >10,000-20,000 | 13.60% and above | 14.40% and above | 15.60% and above | 72 months | 1% |
| >20,000-30,000 | 13.40% and above | 13.80% and above | Not provided | | |
| >30,000-50,000 | 12.60% and above | 13.20% and above | | 84 months | |
| >50,000-70,000 | 12% and above | 12.60% and above | | | |

តារាងទី៤

## ៣.៦ របៀបសងប្រាក់

ធនាគារឡូន: អាស៊ីចំកាត់បានបែងចែករបៀបសងប្រាក់ជាបីប្រភេទគឺ៖

- ទូទាត់ប្រាក់ដើមជារៀងរាល់ខែស្មើៗគ្នា, ទូទាត់ប្រាក់ដើមជារៀងរាល់បីខែម្តងស្មើៗគ្នា, ទូទាត់ប្រាក់ដើមជារៀងរាល់ប្រាំមួយខែម្តងស្មើៗគ្នា(EMP)។

ចំណាំ ទូទាត់ប្រាក់ដើមជារៀងរាល់ខែស្មើៗគ្នា, ទូទាត់ប្រាក់ដើមជារៀងរាល់បីខែម្តងស្មើៗគ្នា, ទូទាត់ប្រាក់ដើមជារៀងរាល់ប្រាំមួយខែម្តងនៃកម្ចីខ្នាតតូចអាចមានចំនួនមិនស្មើគ្នាអាស្រ័យលើ

[29] តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីឥណទានភាគ១, ២០១៦ ទំព័រ៣២
[30] តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីឥណទានភាគ១, ២០១៦ ទំព័រ៣២

សមត្ថភាព បង់សង និងការរកចំណូលរបស់អ្នកខ្ចី។ ប៉ុន្តែចំនួនសំណងប្រាក់ដើមចុងក្រោយមិនត្រូវលើសពី២០%នៃកំចីដែលបានផ្តល់ជូន។

- ទទួលប្រាក់ដើមនិងការប្រាក់ជារៀងរាល់រៀងរាល់ខែស្មើៗគ្នា(EMI)ចាប់ផ្តើមពីខែដំបូងនៃកាលបរិច្ឆេទផ្តល់កម្ចី។ ការប្រាក់នឹងត្រូវទូទាត់ប្រចាំខែចាប់ផ្តើមពីខែបន្ទាប់នៃកាលបរិច្ឆេទបញ្ចេញប្រាក់កម្ចីឥណទានអាជីវកម្មខ្នាតតូច។
- តាមរយៈវិធីចម្រុះ(Variable)

## ៣.៧ ហានិភ័យឥណទាន និងមូលហេតុបណ្តាលឲ្យមានហានិភ័យ

### ៣.៧.១ ហានិភ័យឥណទាន

ហានិភ័យឥណទានដែលអាចកើតមានឡើងក្នុងធនាគារវឌ្ឍនៈ អាស៊ីចំកាត់មានដូចជាៈ

- ហានិភ័យការប្រាក់ កើតឡើងដោយសារតែមានការប្រែប្រួលនូវអត្រាការប្រាក់ដែលអាចផ្តល់ផលវិជ្ជមាន និងអវិជ្ជមានទៅលើទុនរបស់ធនាគារ។
- ហានិភ័យប្រតិបត្តិការ កើតឡើងដោយសារការបរាជ័យនៃការត្រួតពិនិត្យ។
- ហានិភ័យវត្ថុបញ្ចាំ កើតឡើងពេលដែលតំលៃទ្រព្យបញ្ចាំមានការប្រែប្រួល។

### ៣.៧.២ មូលហេតុដែលបណ្តាលឲ្យមានហានិភ័យ

មូលហេតុដែលបណ្តាលឲ្យមានហានិភ័យនៅក្នុងធនាគារវឌ្ឍនៈ អាស៊ីចំកាត់គឺបណ្តាលមកពីកត្តាបីយ៉ាងដូចខាងក្រោមៈ

- កត្តាខាងក្នុង ( Internal Factors )
  - វាយតំលៃ សិក្សាកម្ចីមិនច្បាស់លាស់ និងមិនសិក្សាអំពីប្រវត្តិខ្ចីសងរបស់ភ្ញៀវមិនបានត្រឹមត្រូវ
  - ការសិក្សារបាយការណ៍ចំនេញខាត ទ្រព្យសម្បត្តិ ដើមទន់ ហានិភ័យ និងបង្វៃលគោលបំណងរបស់ភ្ញៀវ ដើម្បីបានខ្ចី
  - បំប៉ោងប្រាក់ចំណូលភ្ញៀវដោយជួយបង្កើតចំណូលបន្ថែមអោយភ្ញៀវ ដើម្បីអោយបានខ្ចីច្រើន
  - វាយតំលៃទ្រព្យដាក់បញ្ចាំមិនច្បាស់លាស់ ( ជឿអាជ្ញាធរ១០០%)
  - អនុវត្តប្រាសចាកគោលនយោបាយ និងនិតិវិធីការផ្តល់កម្ចី
  - ប្រមូលព័ត៌មានភ្ញៀវមិនបានគ្រប់គ្រាន់លើគំរូវការ និងហានិភ័យ មិនមានការតាមដានកម្ចី បន្ទាប់ពីទំលាក់កម្ចី

- ផ្តល់កម្ចីតាមអារម្មណ៍ មនោសញ្ចេតនា និងតាមផែនការ
- ខ្វះក្រមសីលធម៌ក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរ និងអតិថិជន
- ផ្តល់កម្ចីឆ្ងាយ មិនអាចត្រួតពិនិត្យ និងគ្រប់គ្រងបាន
- ឃុបឃិតជាមួយភ្ញៀវ ដើម្បីផ្តល់កម្ចីជួយកម្ចី រឺចែកគ្នា
- សិក្សា និងផ្តល់កម្ចីដែលខុចពីស្ថាប័នដទៃ
- ចំនេះដឹង និងជំនាញនូវមានកំរឹតក្នុងការវាយតំលៃកម្ចី
- មិនមានបទពិសោធន៍លើអាជីវកម្មនោះ និងមិនបានត្រៀមសំណួរ ឬរកប្រភពព័ត៌មានដែលទាក់ទងនឹងអាជីវកម្មនោះ មុននឹងទៅពិភាក្សាជាមួយនឹងភ្ញៀវ

– កត្តាខាងក្រៅ ( External Factors )

- ប្រើប្រាស់កម្ចីខុសគោលបំណង
- ភ្ញៀវមានអំនាច មានអត្តចរិតមិនល្អ និងភ្ញៀវមានជំងឺ
- មានបញ្ហាក្នុងគ្រួសារ ( ប្តី ឬប្រពន្ធបែកបាក់គ្នា )
- បរាជ័យក្នុងមុខរបរ ឬមុខរបរដួលរលំ នាំអោយប្រាក់ចំណូលថយចុះ ឬគ្មានប្រាក់ចមណូល
- ជំពាក់បំណុលច្រើនហួស ( ឯកជន នឹងស្ថាប័នហិរញ្ញវត្ថុដ៏ទៃ )
- មានចេតនាមិនចង់សង ( គ្មានឆន្ទះ) ឬរត់ចោលស្រុក
- ឈរឈ្មោះខ្ចីអោយគេ ដើម្បីទទួលបានអត្ថប្រយោជន៍។

– កត្តាគ្រោះធម្មជាតិ ( Disasters )

- គ្រោះខ្យល់ព្យុះ
- គ្រោះទឹកជំនន់
- គ្រោះរាំងស្ងួត
- គ្រោះរញ្ជួយដី
- គ្រោះបន្ទុះភ្នំភ្លើង
- សង្គ្រាមស៊ីវិល រាំរ៉ៃ
- បរិយាកាសសេដ្ឋកិច្ច និងនយោបាយប្រែប្រួល។

## ៣.៨ ការគ្រប់គ្រងហានិភ័យឥណទាន

### ៣.៨.១ ការត្រួតពិនិត្យឥណទានឡើងវិញ

ការត្រួតពិនិត្យឥណទាន គឺជាដំណើរការពិនិត្យការអនុវត្តតាមលក្ខខណ្ឌ និងរយៈពេលដែលបានអនុម័តដោយគណកម្មាការ ក្រោយពេលដែលកម្ចីត្រូវបានទំលាក់អោយប្រើប្រាស់។

- **ត្រួតពិនិត្យការបើកប្រាក់**គឺជាការចាំបាច់ដើម្បីឲ្យប្រាកដថាការបើកប្រាក់ត្រូវបានធ្វើស្របតាមលក្ខណ្ឌនិងរយៈពេលដែលបានអនុម័ត និងអនុវត្តតាមគោលនយោបាយផ្ទៃក្នុងទាំងស្រុង។ ការងារនេះនឹងជួយទាញយកភាពលំអៀង កំហុសឆ្គង និងការពារការបន្លំលួចប្រាក់។
- **ការត្រួតពិនិត្យការប្រើប្រាស់កម្ចី**គឺជាការចាំបាច់ ដើម្បីឲ្យប្រាកដថាកម្ចីដែលបានយកទៅប្រើប្រាស់ចំគោលបំណងដែលបានស្នើរ។
- **ត្រួតពិនិត្យទ្រព្យធានាជាប្លង់ទន់** ធនាគារផ្តល់កម្ចីដោយទទួលយកទាំងប្លង់ទន់ និងប្លង់រឹងជាទ្រព្យធានា ហើយជារឿយៗ មន្ទីសុរិយោដីបន្តផ្តល់ប្លង់រឹងជាបន្តបន្ទាប់ ដោយប្តូរយកប្លង់ចាស់ត្រលប់ទៅវិញ។ ករណីនេះចាំបាច់ត្រូវតែមានការតាមដាន និងត្រួតពិនិត្យ។

### ៣.៨.២ ឥណទានមានបញ្ហា និងដំណោះស្រាយ

ឥណទានមានបញ្ហាជាឥណទានដែលដែលភ្ញៀវមិនបានមកដាក់ប្រាក់សងបំណុល បានទាន់ពេលកំណត់ តាមកិច្ចសន្យាខ្ចីបរិភោគ និងតារាងសងប្រាក់។

- **វិធានការដោះស្រាយរបស់ Branch ៖**

➢ យឺតយ៉ាវចាប់ពី១៨ថ្ងៃ ចេញលិខិតជូនដំណឹងលើកទី១

➢ ចេញលិខិតជូនដំណឹងជាលើកទី២ ( ប្រសិនលើកទី១មិនបានផល )

➢ ចេញលិខិតជូនដំណឹងជាលើកទី៣ ( ប្រសិនលើកទី១/ទី២មិនបានផល )

➢ លិខិតមេធាវីប្រសិនបើចាំបាច់

➢ សហាការជាមួយ Recovery ដើម្បីរកវិធីដោះស្រាយ ( Reschedule )

➢ ចាត់វិធានការផ្លូវច្បាប់ ប្រសិនបើចំណាត់ការខាងលើមិនបានផល ដោយសហាការជាមួយ Recovery & Legal

➢ សំរេចចិត្តថាផ្ទេរទៅ HO

➢ ចាត់តាំងមេធាវី។

- **វិធានការដោះស្រាយរបស់ផ្នែក Recovery ៖**

➢ ចាប់ពី១សប្តាហ៍ ស្នើរការពន្យល់ពីមន្ត្រីឥណទានសាខា និងស្នើរអោយ LO ចុះពិនិត្យអាជីវកម្ម/ទ្រព្យធានា

➢ ត្រួតពិនិត្យលើការចេញនូវរាល់លិខិតជូនដំណឹង

➢ លើសពី១ខែ ត្រូវចុះត្រួតពិនិត្យអាជីវកម្ម និងវត្ថុធានា

➢ ពិភាក្សាដោយផ្ទាល់ជាមួយភ្ញៀវ/អ្នកធានាជាមួយនឹង LO, MBLS, DSM-L, BM ដើម្បីរកដំណោះស្រាយ ( Reschedule )

➢ សហការជាមួយផ្នែកច្បាប់ដោយចេញលិខិតមេធាវី

➢ វិធានការតុលាការ

➢ អាចចាត់ចែងចុះត្រួតពិនិត្យដោយសំងាត់។

- **វិធានការដោះស្រាយរបស់ Legal ៖**

➢ រៀបចំវិធានការផ្លូវច្បាប់

➢ សហការនូវរាល់ដំណាក់កាលនៃប្រព័ន្ធតុលាការ ( ទទួលដីការកោះ សវនាការ ជាដើម )

➢ សហការជាមួយតំណាងមេធាវី ដើម្បីអនុវត្តដោយបង្ខំ

➢ ត្រូវចូលរួចរាល់នីតិវិធីនៃដំណើរការលក់ឡាយឡុង

➢ ប្រសិនបើក្នុងដំណាក់កាលនៃនីតិវិធីតុលាការ ភ្ញៀវចង់ទូទាត់ គឺអាចចូលរួមពិភាក្សាជាមួយអ្នកអោយខ្ចីរកដំណោះស្រាយសំរាប់ការទូទាត់បាន។

# ជំពូកទី ៤
# ការវិភាគលើការស្ទង់ មតិរបស់អតិថិជន និងការ វាយតម្លៃទៅលើការផ្តល់ សេវាកម្មរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់

# ជំពូកទី៤
# ការពិភាក្សាលើការស្ទង់មតិរបស់អតិថជន និងការវាយតំលៃទៅលើការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់

## ៤.១ ការពិភាក្សាទៅលើមតិរបស់អតិថិជន

ដើម្បីដឹងពីមតិយោបល់របស់អតិថិជនយល់បែបណាពីការផ្តល់ឥណទានរបស់ធនាគារ និងដើម្បីបំពេញទៅតាមតំរូវការរបស់អតិថិជនចំពោះធនាគារ។ ហេតុនេះហើយទើបក្រុមរបស់យើងខ្ញុំសំរេចចិត្តធ្វើការស្រង់មតិអតិថិជននៅក្នុងធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ចំនួន៣៣នាក់ដោយផ្ទាល់ ថាតើពួកគាត់មានយោបល់ និងតំរូវការអ្វីខ្លះពីការផ្តល់ឥណទានរបស់ធនាគារនេះ។

### ៤.១.១ ការស្ទាបស្ទង់មតិយោបល់របស់អតិថជនលើធនាគារទូទៅ

ឆ្លងតាមការសាកសួរស្រង់មតិអតិថិជនចំនួន៣៣នាក់រួចមក យើងឃើញថាក្នុងនោះមានប្រុសចំនួន១៨នាក់ ឯស្រីមានចំនួន១៥នាក់ ហើយពួកគាត់សុទ្ធតែធ្លាប់បានស្គាល់ពីធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ទាំងអស់។ ស្របជាមួយគ្នានេះដែរ អតិថិជនទាំង៣៣នាក់ គឺបានស្គាល់ពីសេវាកម្មឥណទាន ដោយយោងតាមប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដូចជា តាមរយៈមិត្តភក្តិមាន៣០.៣% គ្រួសារមាន២១.២១% វិទ្យុមាន០% ទូរទស្សន៍មាន៣០.៣% កាសែតមាន០% ទស្សនាវដ្តីមាន០% ការផ្សព្វផ្សាយផ្សេងៗមាន ១៨.១៨%។



ជាពិសេសនៅក្នុងចំណោមអតិថិជនដែលបានស្រង់មតិទាំង៣៣នាក់ ក្នុងនោះមានប្រមាណ ៦០.៦០% បានគិតថាពេលស្នើរសុំឥណទានពីធនាគារវឌ្ឍនៈ អាស៊ី ចំកាត់គឺប្រើរយៈពេលឆាប់រហ័ស ហើយប្រមាណ ២១.២១% បានគិតថាពេលស្នើរសុំគឺងាយស្រួលក្នុងការបំពេញឯកសារ និងប្រមាណ ១៥.១៥% បានគិតថាពេលស្នើរសុំគឺមិនចាំបាច់ទាមទារឯកសារច្រើន។




តាមការសាកសួរស្រង់មតិរបស់អតិថិជនរួចមក ពួកគាត់មួយចំនួនធំមានយោបល់ថា ការប្រើប្រាស់សេវាកម្មឥណទានអាចផ្តល់ផលប្រយោជន៍ដល់ពួកគាត់យ៉ាងច្រើន ដូចជាផ្តល់ទុនក្នុងការប្រកបរបរសព្វថ្ងៃពេលពួកគាត់កំពុងមានតកម្រូវការចាំបាច់ដើម្បីដោះស្រាយបញ្ហាផ្សេងៗ និងអាចកែលំអកម្រិតជីវភាពរបស់ពួកគាត់អោយកាន់តែបានប្រសើរជាងមុន។ ប៉ុន្តែទន្ទឹមនឹងឥណទានអាចផ្តល់ផលប្រយោជន៍ច្រើនដល់ពួកគាត់ ពួកគាត់ក៏មានការបារម្ភក្នុងការប្រើប្រាស់នូវឥណទាននោះដែរ ដូចជានៅពេលដែលពួកគាត់មិនមានលទ្ធភាពក្នុងការសងត្រលប់នូវកម្ចៃទាន់ពេលវិញ ដែលវាជាហេតុនាំអោយមានការរឹមអូសរាល់ត្តុបញ្ចាំរបស់ពួកគាត់ និងធ្វើអោយពួកគាត់បានបាត់បង់នូវកេរ្តិ៍ឈ្មោះជាដើម។

**៤.១.២ ការស្ទាបស្ទង់មតិយោបល់របស់អតិថិជនលើធនាគារវឌ្ឍនៈ អាស៊ីចំកាត់**

ទន្ទឹមនឹងនេះដែរអតិថិជនប្រមាណ ៤២% បានយល់ថាភ្នាក់ងារផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ មានភាពរួសរាយរាក់ទាក់ ប្រមាណ ២៤.២៤% យល់ថាបុគ្គលិកធ្វើការមានភាពរហ័សទាន់ចិត្ត ហើយប្រមាណជា ២០% យល់ថារាល់ការងាររបស់ពួកបុគ្គលិកគឺអាចឆ្លើយតបទៅតាមតម្រូវការរបស់អតិថិជនបាន និងមានប្រមាណ ៣.០៣% គិតថាពួកគេមិនអាចឆ្លើយតបទៅបានតាមតម្រូវការរបស់អតិថិជនឡើយ។




ស្របពេលជាមួយគ្នានេះដែរអតិថិជនប្រមាណជា ៧៥.៧៥% យល់ថាភ្នាក់ងារឥណទានបានផ្ដួចផ្ដើមយោបល់ ហើយប្រមាណជា ២១.២១% បានជួយបណ្ដុះបណ្ដាល និងប្រមាណជា ៣.០៣% មិនបានជួយបណ្ដុះបណ្ដាលមុខរបររបស់ពួកគាត់ឡើយ។




មានអតិថិជនប្រមាណ ៧៥.៧៥% បានផ្ដល់មតិថាទីតាំងរបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ស្ថិតនៅជិតនឹងទីកន្លែងរបស់ពួកគាត់ស្នាក់នៅតែម្ដង ហើយក៏មានអតិថិជនប្រមាណ ២៤.២៤% បានផ្ដល់មតិថាទីកន្លែងរបស់ធនាគារស្ថិតនៅមិនឆ្ងាយ ហើយក៏មិនជិតពីទីកន្លែងរបស់ពួកគាត់ដែរ ។




## ៤.២ ការវាយតំលៃ និងវិភាគលើធនាគារធនាគារវឌ្ឍនៈ អាស៊ី ចំកាត់

### ៤.២.១ ការវាយតំលៃលើធនាគារវឌ្ឍនៈ អាស៊ី ចំកាត់

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវពីគោលនយោបាយ និងការចុះកម្មសិក្សាសោយផ្ទាល់ទៅលើផ្នែកឥណទានរបស់ធនាគារធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ រួមទាំងការធ្វើការស្រង់មតិផ្ទាល់ពីអតិថិជនរបស់ធនាគារ យើងសង្កេតឃើញថាសក្តានុពល់របស់ធនាគារពិតជាមានភាពរីកចំរើនស្ទើរគ្រប់ខេត្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជាទីទុកចិត្ត និងជាទីពឹងពាករបស់ប្រជាជនដែលជាអតិថិជននៅតាមទីជនបទ ជាពិសេសរបស់អតិថិជនដែលមានដែលមានកង្វះខាត។ ជាងនេះទៅទៀតយើងសង្កេតឃើញថា រាល់សកម្មភាពរបស់ធនាគារបានឆ្លុះបញ្ចាំងពីភាពជោគជ័យរបស់ខ្លួននៅលើទីផ្សារតាមរយៈការបង្កើតនូវសាខាជាច្រើនកន្លែងស្ទើរគ្រប់ខេត្តក្រុងក្នុងប្រទេសទាំងមូល ហើយការបង្កើតនូវសេវាផ្ទេរប្រាក់ក្នុងស្រុក គួបផ្សំជាមួយសកម្មភាពដ៏រួសរាយរាក់ទាក់របស់បុគ្គលិក និងការសហការគ្នាទៅវិញទៅមករវាងបុគ្គលិក និងបុគ្គលិក អតិថិជន និងបុគ្គលិកជាដើម។ យោងតាមការចុះកម្មសិក្សាផ្ទាល់ផ្នែកឥណទាននៃធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ យើងបានស្វែងរកឃើញនូវចំនុចខ្លាំង និងចំនុចខ្សោយរបស់ធនាគារនេះ។

### ៤.២.២ ចំនុចខ្លាំង

ក្នុងរយៈពេលនៃការចុះកម្មសិក្សាផ្ទាល់ យើងសង្កេតឃើញថាធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ មានចំនុចខ្លាំងជាច្រើនដែលអាចធ្វើអោយធនាគារនេះមានភាពរីកចំរើនយ៉ាងឆាប់រហ័សដែលក្នុងនោះរួមមាន៖

- មិនយកកម្រៃសេវាលើការវាយតំលៃអចលនទ្រព្យ និងមេធាវី
- ប្រើប្រាស់ប្រព័ន្ធបច្ចេកទេសស្វ័យប្រវត្ត ដែលនាំឲ្យមានដំណើរការឆាប់រហ័ស
- មិនទទួលយកលុយពីភ្ញៀវ
- មានបែបបទជាលក្ខណៈស្តង់ដាទៅតាមបទបញ្ញាត្តិ និងសេចក្តីណែនាំរបស់ធនាគារជាតិ
- មានគោលនយោបាយច្បាស់លាស់ ជាហេតុនាំអោយបុគ្គលិកទាំងអស់ក៏ដូចជាភ្នាក់ងារឥណទានអនុវត្តការងារបានយ៉ាងរលូន និងងាយស្រួល
- អតិថិជនគ្រប់ជាន់ថ្នាក់អាចទទួលបានឥណទានពីធនាគារ
- រក្សាការសំងាត់ជូនអតិថិជន និងរក្សាទុកនូវឯកសារអចលនវត្ថុប្រកបដោយសុវត្ថិភាព
- មានការលើកលែងប្រាក់ពិន័យដល់អតិថិជនដែលបង់យឺតពេលក្នុងករណីចាំបាច់
- មានរចនាសម្ព័ន្ធត្រឹមត្រូវដែលបញ្ជាក់ពីតួនាទី និងការងាររបស់បុគ្គលិកគ្រប់រូប
- មានការយកចិត្តទុកដាក់ចំពោះអតិថិជនលើគ្រប់សកម្មភាព ចាប់ពីពេលដែលអតិថិជនមកធ្វើការស្នើរសុំឥណទាន រហូតដល់ពេលដែលអតិថិជនបានសងប្រាក់ដល់ធនាគារអស់ ដែលនេះបានបង្ហាញពីការបំពេញនូវសេចក្តីត្រូវការរបស់អតិថិជន នេះជាហេតុនាំអោយសក្តានុពលភាពរបស់ធនាគារមានការកើនឡើង
- តាមការវិភាគស្ទាបស្ទង់មតិរបស់អតិថិជនបានឆ្លើយថា រាល់បុគ្គលិករបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ គឺមានភាពរួសរាយរាក់ទាក់ និងមានសាមគ្គីភាពដែលបានបង្កអោយមានភាពងាយស្រួលក្នុងការអនុវត្តការងារ និងកាប្រាស្រ័យទាក់ទងគ្នារវាងបុគ្គលិក និងបុគ្គលិក ព្រមទាំងរវាងអតិថិជន និងបុគ្គលិក។
- តាមការវិភាគស្ទាបស្ទង់មតិរបស់អតិថិជន យើងបានយល់ថាដំណើរការបំពេញសុំឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ មានលក្ខណៈងាយស្រួល និងឆាប់រហ័ស។
- តាមការវិភាគស្ទាបស្ទង់មតិរបស់អតិថិជនបានអោយដឹងថា ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ បានជួយផ្តល់យោបល់ និងផ្តល់ការបណ្តុះបណ្តាលអំពីមុខរបររបស់អតិថិជន ក្នុងគោលបំណងដើម្បីអោយពួកគាត់មានលទ្ធភាពក្នុងការសងប្រាក់ត្រលប់មកជូនធនាគារវិញ។

### ៤.២.៣ ចំនុចខ្សោយ

ទន្ទឹមនឹងភាពរីកចំរើន និងចំណុចខ្លាំងដ៏ច្រើននោះ ធនាគារក៏ប្រឈមមុខនឹងចំណុចខ្សោយមួយចំនួនផងដែរ ដែលក្នុងនោះរួមមាន៖

- តាមរយៈការស្ទង់មតិរបស់អតិថជន ឃើញថាកម្រិតអត្រាប្រាក់ខ្ពស់ ដែលបណ្តាលឲ្យអតិថិជនមួយចំនួនពិបាកទទួលយក ដែលធ្វើឲ្យពួកគាត់អាចនឹងស្វែងរកធនាគារផ្សេងដែលមាន អត្រាការប្រាក់ប្រហាក់ប្រហែល ឬទាបជាង។
- តម្រូវការឯកសារច្រើន ដែលបណ្តាលឲ្យអតិថជនចំណាយពេលវេលាច្រើនក្នុងការរៀបចំ
- តាមការស្ទង់មតិរបស់អតិថជនយល់ថា អាកប្បកិរិយារបស់ភ្នាក់ងារផ្តល់ឥណទានមួយចំនួនមានលក្ខណៈយឺតយ៉ាវ ដែលធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់អតិថិជន។
- តាមការស្ទង់មតិរបស់អតិថជនយល់ថា ទីតាំងរបស់ធនាគារនៅមិនជិត ពីកន្លែងស្នាក់នៅដែលធ្វើឲ្យអតិថជនពិបាកក្នុងការប្រើប្រាស់សេវាកម្មរបស់ធនាគារ។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីចុះកម្មសិក្សា ធ្វើការស្រាវជ្រាវ និងស្រង់យកទិន្នន័យតាមរយៈការសាកសួរ ការវិភាគទិន្នន័យលើការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ សាខាស្ទឹងមានស្ទឹងមានជ័យរួច យើងអាចសន្និដ្ឋានបានថា ការផ្តល់ឥណទាន នៅធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ពិតជាបានរួមចំណែកយ៉ាងខ្លាំងក្នុងការជំរុញនូវការលើក កំពស់ជីវភាពរបស់ប្រជាជនឲ្យកាន់តែប្រសើរឡើង និងបំពេញនូវសេចក្តីត្រូវការដែលអតិថជនចង់បាន ដែលនេះជាហេតុនាំឲ្យសេដ្ឋកិច្ចជាតិមានការរីកចំរើន។ មិនតែប៉ុនោះ ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ បានធ្វើការគ្រប់យ៉ាង ម៉ត់ចត់ នឹងតឹងរឹងដោយអនុវត្តន៍តាមគោលនយោបាយរបស់ធនាគារ ដែលបានកំណត់យ៉ាងច្បាស់លាស់ ដោយភ្ជាប់ជាមួយការវិភាគទៅលើស្ថានភាពរបស់អតិថជន ការចុះទៅដល់ទីកន្លែងរបស់អតិថជន ការសាកសួរពត៌មានពីអតិថជន និងអាជ្ញាធរដែនដីយ៉ាងយកចិត្តទុកដាក់ ព្រមទាំងការបំពេញសំណុំឯកសារយ៉ាងម៉ត់ចត់ និងត្រឹត្រូវដើម្បីជាមធ្យោបាយមួយក្នុងការកាត់បន្ថយនូវហានិភ័យរបស់ធនាគារ ក៏ដូចជាអតិថជនផងដែរ។ ជាពិសេស ដើម្បីឲ្យគ្រឹះស្ថានកាន់តែមានសក្តានុពលភាពនោះ រាល់បុគ្គលិកទាំងអស់ចាប់តាំងពីថ្នាក់ដឹកនាំរហូតដល់បុគ្គលិកត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍ការងារ ព្រមទាំងក្រមសីលធមិ និងការចេះរួមសហការគ្នាយ៉ាងល្អរវាង បុគ្គលិក និងបុគ្គលិក និងពីផ្នែកមួយទៅផ្នែកមួយ។ ម្យ៉ាងវិញទៀតយើងសង្កេតឃើញថា ធនាគារបានផ្តោតសំខាន់ផងដែរទៅលើការរក្សាអតិថជនរបស់ខ្លួន និងការបំពេញតម្រូវរបស់អតិថជនទាំងអស់។

ដោយការអនុវត្តលើគោជំហរទាំងអស់នេះ បានធ្វើឲ្យការផ្តល់ឥណទានរបស់ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ទទួលបានការពេញចិត្តយ៉ាងខ្លាំងពីអតិថជនដែលបានប្រើប្រាស់សេវាឥណទានរបស់ធនាគារ។ ជាពិសេសធនាគារវឌ្ឍនៈ អាស៊ីចំកាត់ បានអនុវត្តតាមទ្រឹស្តីដែលបានលើកឡើងស្ទើរតែមួយរយភាគរយ ថ្វីត្បិតតែមានចំនុចខ្វះខាត់មួយចំនួនតូច ដែលក្នុងនោះកត្តាសំខាន់បំផុតគឺទាក់ទងទៅនិងអត្រាការប្រាក់ ដែលផ្តល់ជូនអតិថជន និងតម្រូវការឯកសារច្រើន។ ទោះជាយ៉ាងណាក៏ដោយបញ្ហាទាំងអស់នោះពុំអាចរាំងការរីចម្រើនរបស់ធនាគារបានទេ ផ្ទុយទៅវិញធនាគារវឌ្ឍនៈ អាស៊ីចំកាត់នៅតែបន្តការរីចម្រើនពីមួយឆ្នាំទៅមួយឆ្នាំដោយមានការទទួលស្គាល់ពីប្រជាជនកម្ពុជា និងបរទេសថែមទៀតផង។

## ២. ការផ្តល់អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាយ៉ាងយកចិត្តទុកដាក់ អំពីធនាគារវឌ្ឍនៈអាស៊ីចំកាត់ តាមរយៈការចុះកម្មសិក្សាផ្ទាល់ ការស្ទង់មតិអតិថជន និងការវិភាគទិន្នន័យដែលទទួលបានទាំងអស់រួចមក យើងសង្កេតឃើញថាធនាគារគួរសិក្សាឡើងវិញលើចំនុចខ្វះខាត់ដែលមាន នឹងពង្រឹងបន្ថែមទៀតលើចំនុចខ្លាំងរបស់ខ្លួនដែលមានស្រាប់ដើម្បីវិវត្តខ្លួនឲ្យឈានទៅកាន់ការចាប់អារម្មណ៍ខ្ពស់ជាងគេ ក្នុងចំនោមធនាគារធំៗដទៃទៀតនៅក្នុងប្រទេសកម្ពុជា។

ក្នុងនោះចំនុចដែលគួរកែលំអ្មឡើងវិញមានដូចជា៖

- ការពិចារណាទៅលើកម្រិតនៃអត្រាការប្រាក់ ទាំងផ្នែកឥណទាន និងបញ្ញើឡើងវិញដើម្បីបំពេញតាមសំណូមពររបស់អតិថជន។ កត្តាអត្រាការប្រាក់នេះ មិនត្រឹមតែអាចបំពេញតាមសេចក្តីពេញចិត្តរបស់អតិថជនតែប៉ុនោះទេ វាថែមទាំងអាចទាក់ទាញអតិថជនថ្មីៗទៀតឲ្យមកកាន់ធនាគារកាន់តែច្រើនឡើង។
- ធនាគារ គួរតែកាត់បន្ថយនូវឯកសារមួយចំនួនដែលមិនចាំបាច់ ដោយយកតែឯកសារណាដែលមានសារៈសំខាន់ក្នុងការវិភាគអតិថជន ដែលជួយសម្រួលដល់ការស្នើសុំឥណទានរបស់អតិថជកាន់តែឆាប់រហ័ស។
- ធនាគារ គួរតែពង្រឹងនូវយុទ្ធសាស្ត្រ និងគោលនយោបាយចំពោះបុគ្គលិកឲ្យបានតឹងរឹងរាល់សកម្មភាពរបស់បុគ្គលិក ក្នុងការដោះស្រាយបញ្ហាជូនដល់អតិថជនឲ្យបានល្អ និងស្របតាមតម្រូវការរបស់អតិថជន។ ការអនុវត្តនេះ អាចធ្វើបានទាមរយៈ ការសង្កេត វាយតម្លៃឲ្យបានម៉ត់ចត់ និងការកំណត់វិន័យផ្សេងៗ ដើម្បីឲ្យបុគ្គលិកបំពេញតាមតួនាទីរបស់ខ្លួនបានត្រឹមត្រូវ។
- ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ គួរតែពង្រីកសាខាបន្ថែមទៀត ដើម្បីផ្តល់លក្ខណៈងាយស្រួលដល់អតិថជនក្នុងការប្រើប្រាស់សេវាកម្មរបស់ធនាគារ។

ជាចុងក្រោយនេះ យោងតាមការស្រាវជ្រាវ សង្ឃឹមថាការផ្តល់មតិយោបល់ទាំងនេះ នឹងអាចជួយជាគំនិតមួយផ្នែកដល់ ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ ក្នុងការអភិវឌ្ឍន៍ឲ្យបានល្អប្រសើរជាងមុន និងដើម្បី ស្ថាបនាឲ្យមានភាពរីចម្រើនឡើង ក្នុងវិស័យនេះ ដែលទទួលបាននូវទំនុកចិត្ត និងការគាំទ្រពីសាធារណៈជន ឲ្យក្លាយជាធនាគារ លំដាប់លេខមួយ ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ជាពិសេសសេវាឥណទាននេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក

ឈ្មោះ............................ ភេទ............ អាយុ ............ឆ្នាំ និង ឈ្មោះ .......................ភេទ............ អាយុ........ឆ្នាំ អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ................ផ្លូវលេខ..............ភូមិ..............ឃុំ/សង្កាត់.............. ក្រុង/ស្រុក/ខណ្ឌ............. រាជធានី/ខេត្ត.......................... (បុគ្គលមានសិទ្ធិចុះបញ្ជី) និង **ធនាគារវឌ្ឍនៈអាស៊ីចំកាត់ សាខា**.....................ជាធនាគារដែលបាន ចុះបញ្ជី និង ទទួលបានអាជ្ញាប័ណ្ណស្របតាមច្បាប់ និង បទបញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា ព្រមទាំងច្បាប់ពាក់ព័ន្ធផ្សេង ទៀតនៃ ព្រះរាជាណាចក្រកម្ពុជាដែលមានលេខចុះបញ្ជី Co.322/97E និងមានអាសយដ្ឋាននៅអគារលេខ១៤៨ មហាវិថីព្រះសីហនុ សង្កាត់បឹង កេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា(បុគ្គលមានកាតព្វកិច្ចចុះបញ្ជី)។

## សូមគោរពជូន

## លោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ/ខេត្ត.............

**កម្មវត្ថុ៖** សំណើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក

**យោង៖** - មូលហេតុ និងកាលបរិច្ឆេទ................................................

តាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមស្នើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែកដូចខាងក្រោម៖

ក-គោលបំណងនៃការចុះបញ្ជី៖

☑-ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកលេខ............................លើកម្មសិទ្ធិ

☐- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកលេខ............................លើសិទ្ធិជួលអចិន្ត្រៃយ៍

☐- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកលេខ............................លើផលុបភោគ

ខ-មូលហេតុ៖

☑-ការសង ចុះថ្ងៃទី..........ខែ...........ឆ្នាំ...............ឬ

☐-ការបោះបង់សិទ្ធិលើហ៊ីប៉ូតែកចុះថ្ងៃទី.........ខែ...........ឆ្នាំ...............ឬ

☐-ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា ចុះថ្ងៃទី..........ខែ...........ឆ្នាំ...............ឬ

☐-មូលហេតុផ្សេងទៀត................................ចុះថ្ងៃទី..........ខែ...........ឆ្នាំ..............

គ-បុគ្គលមានសិទ្ធិចុះបញ្ជី

-ឈ្មោះ.......................................................................................................................................

-ថ្ងៃ ខែ ឆ្នាំកំណើត និង ទីកន្លែងកំណើត:...................................................................................

-ឈ្មោះឪពុក.................................................................. ឈ្មោះម្តាយ.......................................................................

-អាសយដ្ឋាន: ផ្ទះលេខ.............ផ្លូវលេខ..........ភូមិ.........ឃុំ/សង្កាត់........... ក្រុង/ស្រុក/ខណ្ឌ.............. រាជធានី/ខេត្ត................

-ឈ្មោះ.................................................................................................................................................

